## ៦

# អនុស្សាវរីយ៍

ក្នុងខណៈដែលវិញ្ញាណរបស់ខ្ញុំកំពុងតែគ្របដណ្ដប់ដោយសេចក្ដីសោហ្មងគ្រប់បែបយ៉ាងនោះ ស្រាប់តែមានសំឡេងស្រួយស្រិបមកពុញ្ញាក់ :

- បងបូផាន់ ហេតុអីត្រឡប់មកផ្ទះមុន ហើយអត់ប្រាប់ខ្ញុំអីចឹង !...

ខ្ញុំងាកក្រោយឃើញមាលាដើរចូលមកជិតស្រេច ជាមួយនឹងទឹកមុខព្រួយបារម្ភផង ងឿងឆ្ងល់ផង ។ នាងមកឈរចំពីមុខខ្ញុំសួរបន្ថែម :

- បងមិនស្រួលខ្លួនអី ? . . .

កំពុងតែរកពាក្យដោះសាមិនបានផង ព្រោះឮគេសួរអីចឹង ខ្ញុំខំសំរួលទឹកមុខ ហើយឆ្លើយទាក់បណ្ដោយតែម្ដង :

- បងមិនសូវស្រួលខ្លួនមែន ប៉ុន្តែមិនចង់នាំរំខានដល់មាលា ដែលកំពុងតែសប្បាយក្នុងពិធីបុណ្យ ទើបត្រឡប់មកមុន មិនបាននិយាយប្រាប់មាលា ! . . .

- បងឈឺអី ! ... កោសខ្យល់អ្ហ៎ ! ... ខ្ញុំកោសឲ្យ ! ... (អាកប្បកិរិយារបស់នាងបង្ហាញនូវការយកចិត្តទុកដាក់ចំពោះខ្ញុំពិតប្រាកដមែន )

ខ្ញុំនិយាយថាមិនចង់រំខានការសប្បាយរបស់មាលា គឺមានចំណង



ចំអកបញ្ឈឺឲ្យនាងដឹងខ្លួន ប៉ុន្តែមាលាឥតយល់សោះ បែរជាសំដែងការព្រួយបារម្ភគួរឲ្យអាណិតទៅវិញ ។ ឃើញខ្ញុំនៅស្ងៀមពុំចេញស្ដី នាងកាន់តែរន្ធើនសួរ :

- បងចេះតែយ៉ាងម៉េចនៅក្នុងខ្លួន ? . . .

- បងមិនជាឈឺអីធ្ងន់ទេ ! . . គ្រាន់តែវិលមុខបន្តិចបន្តួចប៉ុណ្ណោះ ពីព្រោះបងមិនសូវចូលចិត្តនៅក្នុងចំណោមមនុស្សច្រើនអ៊ូអរអីចឹង ( នេះជាលើកដំបូង ដែលខ្ញុំនិយាយពាក្យកុហកជាមួយមាលា ) ។

មាលាជ្រួញចិញ្ចើម ៖

- បងធ្លាប់ដើរផ្សារជាមួយនឹងខ្ញុំច្រើនដងរាប់មិនអស់ ។ នៅក្នុងផ្សារមនុស្សច្រៀតជ្រែងគ្នា ហើយក្លិនអាក្រក់ផង ហេតុអីក៏មិនដែលធ្វើទុក ! . . . ដូច្នេះពេលនេះ បងឡាស់ជាខ្យល់ចាប់ហើយ គស់ ! ឡើងទៅលើផ្ទះ ខ្ញុំកោសឲ្យ ! . . . ដល់ពេលចាល់ច្រកមែនទែន ខ្ញុំចេញក្បួនកុហកមួយជាន់ទៀត :

- មិនបាច់កោសទេមាលា ព្រោះឥឡូវនេះ ខ្ញុំបានស្រឡះមុខស្រឡះមាត់ស្រួលខ្លួនវិញហើយ ! . . .

ឆ្នាំនេះ ខ្ញុំអាយុម្ភៃមួយ ឯមាលាទើបតែអាយុដប់ប្រាំពីរឆ្នាំប៉ុណ្ណោះ ។ នាងធ្លាប់ហៅខ្ញុំថា « បងបូផាន់ » តាំងពីយើងនឹងស្គាល់គ្នាមកម្ល៉េះ ។ ឯខ្ញុំវិញក៏ហៅនាងចំឈ្មោះដែរ គឺការនិយាយស្ដីរវាងយើងទាំងពីរនាក់ស្និទ្ធស្នាលដូចបងប្អូនក្នុងរង្វង់ត្រកូលជាមួយគ្នា ។

ឮថាខ្ញុំស្រួលខ្លួនវិញ មាលាប្រែទឹកមុខស្រស់ស្រាយវិញ ហើយ

ថយទៅអង្គុយលើគ្រែឫស្សីនៅកៀនសសរ ហើយរអ៊ូរទាំ ៖

- ខ្ញុំមកតាមបងអម្បាញ់មិញនេះ ក៏មិនបានជំរាបម៉ែ ! . . .

- ម៉េចក៏អីចឹង ! ( ខ្ញុំធ្វើឫកដាប់ទ្រាសនាងម្ដងវិញ )

- ម៉ែកំពុងដាប់រវាប់បាត ។ មនុស្សប្រុសស្រីគ្នាលួចដើរមិនចុះយ៉ាងហ្នឹង ធ្វើម៉េចនឹងចូលទៅជិតគាត់បាន !

- ហេតុអីបានជា មាលាដឹងថាខ្ញុំមកផ្ទះ ? . . .

- ពេលបាត់បងខ្ញុំដើររក ។ លុះសួរគេសួរឯងទៅ ទើបឮម៉ាស់ (ក្រពុំ ជាតិចាមម្នាក់ដែលនៅភូមិជាមួយគ្នា ) . . ប្រាប់ថា ឃើញបងដើរចេញពីវត្ត សំដៅមកផ្ទះវិញ ! . . .

ខ្ញុំនិយាយជាមួយមាលា ហាក់ដូចជាធម្មតាបែន ប៉ុន្តែក្នុងចិត្តកំពុងតែក្ដុកក្ដួលនិងឆាបឆេះដោយភ្លើងប្រច័ណ្ឌ ។ ខ្ញុំខំអត់ធ្មត់ណាស់ ដោយគិតថាមិនត្រូវខឹងនឹងគេទេ ព្រោះខ្លួនមិនមែនជាប្ដីឬជាសង្សាររបស់គេឯណា! ប៉ុន្តែទោះបីជាខំទ្រាំសង្កត់ចិត្តយ៉ាងណា ក៏អារម្មណ៍នៅតែពុះកញ្ជ្រោលដដែល ។

ប្រហែលជាចាប់ទឹកមុខខ្ញុំបាន ទើបមាលាសួរ ៖

- បងកំពុងគិតរឿងអីឬ ! ហ៊ឺ ពេលបុណ្យភ្ជុំបិណ្ឌតាមប្រពៃណីខ្មែរ កូនចៅ ទោះបីនៅជិតឆ្ងាយយ៉ាងណាក៏ដោយ ក៏ត្រូវតែគាត់មកជួបជុំបងប្អូននិងក្រុមគ្រួសារនៅនឹងផ្ទះរបស់ឪពុកម្ដាយដែរ ដូច្នេះពេលនេះប្រហែលជាបងកំពុងតែនឹកស្រណោះខ្លួនហើយមើលទៅ ? ធ្វើម៉េចទៅបងបូធាន់ បើស្រុកកំណើតរបស់បងនៅឆ្ងាយម្ល៉េះ ខ្ញុំក៏អាណិតបងដែរ !



ពាក្យសំដីឈឺផ្សាលដោយស្មោះត្រង់របស់មាលា ធ្វើឲ្យខ្ញុំនឹកអាណិតនាង ហើយកំហួលកំហឹងឈឺចាប់ហាក់ដូចជាស្រាមចុះអស់ពាក់កណ្ដាល នៅសល់តែក្ដីប្រច័ណ្ឌដ៏ងប់ងុលតែប៉ុណ្ណោះ !

ឃើញខ្ញុំចេះតែនៅស្ងៀមមិនស្ដី ប្រហែលជានាងយល់ថា ពាក្យសំដីរបស់នាងអម្បាញ់មិញត្រឹមត្រូវតាមចំណុចចិត្តរបស់ខ្ញុំ បានជាមាលាងើបពីគ្រែមកឈរប្រកិតនឹងអង្រឹងចំមុខនឹងខ្ញុំ ហាក់ដូចជាចង់រកពាក្យពេចន៍មកនិយាយឲ្យរីករាយបន្ធូរសេចក្ដីទុក្ខ មាលាពោលដោយទឹកមុខរីកគ្រេកអរ ៖

- បងបូធាន់ ខ្ញុំភ្លេចប្រាប់រឿងមួយ !

- រឿងអីទៅ ?

- អម្បាញ់មិញនេះ បងសមត្រូវជាបងជីដូនមួយរបស់ខ្ញុំ គាត់ជាអ្នករាជការ ! . . . និមិត្តតែឮឈ្មោះសមនេះ ខ្ញុំឆាបឆេះមួយរំពេច ប៉ុន្តែឮថា ត្រូវជាបងជីដូនមួយរបស់មាលាក៏ត្រជាក់ចិត្តវិញខ្លះ ហើយនិយាយយកគួរសម ៖

- អូ ! គាត់ត្រូវជាបងជីដូនមួយរបស់មាលាទេឬ ! ម៉េចក៏មិននាំឲ្យខ្ញុំស្គាល់ផង ?

- នាំឲ្យស្គាល់ឯណាទាន់ បើពេលងាករកមើលបង ស្រាប់តែបាត់ស្រមោលឈឹង !

ខ្ញុំនឹកអៀនខ្មាសខ្លួនឯង ប៉ុន្តែមិនបង្ហាញឲ្យគេដឹង ។ មាលាក៏ចាប់អារម្មណ៍ទៅតែរៀបរាប់បន្ត ៖

- បងនឹងថា បងសមនិយាយអីទេ ! ជាមួយខ្ញុំ !

- ធ្វើម៉េចនឹងដឹង បើមាលាមិនប្រាប់ ( ខ្ញុំនិយាយធ្វើព្រងើយ ប៉ុន្តែក្នុងពោះច្រាសច្រាល់ចង់ដឹងណាស់ )

- គាត់ប្រុងរកការឲ្យបងធ្វើណា៎ !

- រកការឲ្យធ្វើ ! ធ្វើការស្អីទៅ ?

- ធ្វើជាអ្នករាជការដូចគាត់ដែរណា៎ !

- ហេស ៗ . . . តាមការពិតបងសមនោះ គាត់និយាយលេងទេ ! . . .

- បងសមមិនមែនជាមនុស្សនិយាយពាក្យឥតបានការទេ តែថាយ៉ាងណា គាត់ធ្វើយ៉ាងនោះហើយ ។ គាត់ធ្វើការបានពីរឆ្នាំហើយ ប៉ុន្តែទើបនឹងរៀបការប្រពន្ធមិនដល់មួយឆ្នាំផង !

ស្ដាប់ការបរិយាយរបស់មាលាដល់នេះ ខ្ញុំដូរទ្រូងឲ្យរាកដូចដកបន្ទាចេញពីទ្រូង ព្រោះឮថា បងជីដូនមួយរបស់នាង គេមានប្រពន្ធរួចស្រេចទៅហើយ ។ លើសពីនេះ ខ្ញុំនឹកភ័យក្រោយជាខ្លាំង ព្រោះជាគ្រោះល្អដែរ ដែលខ្ញុំមិនបានបញ្ចេញពាក្យពេចន៍អ្វីឲ្យដឹងថាខ្ញុំប្រច័ណ្ឌនឹងនិង សម ។ បើសិនជាច្រលធ្វើឲ្យនាងដឹង មិនដឹងជាខ្ញុំត្រូវអៀនខ្មាសប៉ុនណាទេ !

ខ្ញុំខិតខំលាក់លៀមទឹកមុខភ្ញាក់ផ្អើល ៖

- ហេតុអីបានគាត់យកចិត្តទុកដាក់នឹងខ្ញុំដល់ម្ល៉េះ បើពុំដែលស្គាល់គ្នាសោះ ! មាលាសើចប្រេះប្រៀន ៖



- គឺពុកបានពឹងពាក់គាត់ ! . . .

- ប្រហែលជាលោកពូមើលទាល់ មិនចង់ឲ្យខ្ញុំរស់នៅជាមួយគេទៀតទេដឹង បានជាគាត់មានបំណងរកការងារឲ្យខ្ញុំធ្វើ ! . . .

មាលាប្រកែកតវ៉ាភ្លាម ៖

- មិនមែនអីចឹងទេ សូមបងកុំយល់ច្រឡំឲ្យសោះ ! . . . តាមការពិត ពុកគាត់ឃើញបងជាមនុស្សល្អគួរ សុភាពរាបសា ស្មោះត្រង់ ឥតដែលមានគំនិតវៀចវេរដល់អ្នកណាសោះ ថែមទាំងរសាត់អណ្ដែតមកពីប្រទេសក្រៅផង ទើបគាត់អាណិតស្រឡាញ់ប្រៀបដូចកូនក្មួយ ! . . ហេតុដូច្នេះហើយបានជាពុកចង់ស្វែងរកអនាគតល្អឲ្យបង! ... ពុកមិនមែនប្រាថ្នាឲ្យបងទៅធ្វើការស៊ីឈ្នួលគេ ឬក៏លីសែងទៀតទេ គឺគាត់ចង់ឲ្យបងចូលធ្វើការក្នុងក្របខ័ណ្ឌរាជការ ទោះជាត្រូវស្អកចាក់អស់ប៉ុន្មានក៏ដោយ !

- ស្ដាប់ដល់នេះ ខ្ញុំកាន់តែរំភើបនិងគោរពដឹងគុណចំពោះទឹកចិត្តសប្បុរសរបស់ពូរ៉ុស ! . . ខ្ញុំក្រោកអង្គុយសំយុងជើងក្នុងអង្រឹងសម្លឹងទៅទឹកទន្លេដែលកំពុងហូរ ហើយជម្រុះវាចាក្នុងការសញ្ជឹងគិត :

- មាលាអើយ ខ្ញុំគ្រាន់តែចេះអក្សរខ្មែរមួយក្ដាប់នោះ ធ្វើម៉េចនឹងអាចចូលធ្វើការក្នុងក្របខ័ណ្ឌរាជការបាន ! . . .

- រឿងនេះពុកក៏ដឹងដែរ ប៉ុន្តែនៅក្នុងវត្តអគ្គញាតមិញ បងសមគាត់និយាយថា បងរៀនសូត្របានខ្ពស់ ! . . . ក្រៅពីភាសាឡាវដែលជាភាសាកំណើត បងចេះភាសាបារាំងច្រើន និងភាសាវៀតណាមផង

ផ្ទះពេលនេះ គាត់សម្លឹងឃើញកន្ទេលដែលត្រូវបញ្ចូលរូបបងទៅធ្វើ
រួចស្រេចទៅហើយ ! . . .

- ហេតុអីបានជាគាត់ដឹងពីកំរិតវប្បធម៌របស់បង ? . .

មាលាសើចរលាក់អាត្មា ហាក់សប្បាយរីករាយណាស់ ៖

- ទាំងពុក ទាំងបងសម សុទ្ធតែបានដឹងអំពីកំរិតការរៀនសូត្រ
របស់បងទាំងអស់ ! . . .

- ខ្ញុំភ្ញាក់ផ្អារពោះ ៖

- ហ្អា ! . . . បើដូច្នោះអ្វីៗក្នុងរឿងនេះ សុទ្ធតែជាគំនិតរបស់
មាលាផ្តើមចេញទាំងអស់មែនទេ ? . .

មាលាមិនឆ្លើយ គ្រាន់តែសើចសារភាពប៉ុណ្ណោះ ! . . ខ្ញុំឈឺ
ក្បាលហួសចិត្ត ៖

- ហេតុអីបានជាមាលា មិនពិគ្រោះនឹងខ្ញុំសិន ?

មាលាស្រញូចចិញ្ចើម :

- បងយល់ថា ខ្ញុំបានធ្វើមិនល្អចំពោះបងឬ ?

- មាលានិងលោកពូ មិនគួរគិតគូរដល់ខ្ញុំ រហូតដល់ថ្នាក់ហ៊ានចំ
ណាយទ្រព្យសម្បត្តិអីចឹងសោះ :

- មកដល់ថ្ងៃនេះហើយ បងនៅតែមិនយល់ចិត្តខ្ញុំទៀត ! . . .
មិនដឹងជាមានវិស័យអ្វី បានជាខ្ញុំចេះតែអាណិតបងតាំងពីថ្ងៃដែល
បានឃើញបងជាលើកដំបូងនៅឯកំពង់ផែម្លេះ ! . . .

- ហ៊ឺ . . ខ្ញុំជំពាក់គុណគ្រួសារមាលាច្រើនណាស់ ! . . មិនដឹង



ជាបានអ្វីតបស្នងសងគុណវិញទេ ! . . .

មាលាហាក់មិនរវល់នឹងពាក្យរបស់ខ្ញុំ នៅតែខំបង្វែងទៅរឿង
ចាស់ដដែលវិញ ! . . .

- បងសមក៏ចូលចិត្តនិងស្រឡាញ់រាប់អានបងដែរ គ្រាន់តែពុំមាន
បានជួបនិយាយគ្នាប៉ុណ្ណោះ ! . . .

- មិនដែលស្គាល់គ្នាផង ហេតុអីក៏បងសមចូលចិត្តខ្ញុំ ! . . .

- ព្រោះគាត់បានស្គាល់ការរៀបរាប់របស់ខ្ញុំនិងពុក អំពីឫកពានិង
ចរិយារបស់បង ! . . . គាត់ផ្តាំថា ថ្ងៃនេះពុំបានមកលេងផ្ទះយើង
ទេ ប៉ុន្តែពីរបីថ្ងៃទៀត គាត់សុំឱ្យពុកនាំបងទៅជួបនឹងគាត់ ដើម្បី
បញ្ជាក់និងរៀបចំធ្វើសំណុំលិខិតផ្សេងៗសុំចូលធ្វើការ ! . . .

ខ្ញុំអស់សំណើចខ្ចិច ទើបនាំចិត្តពោល ៖

- មាលា បើខ្ញុំនិយាយរឿងមួយ តើមាលាអន់ចិត្តទេ ? . . .

- រឿងអីទៅ បងបូផាន់ ?

- បងរំភើបត្រេកអរណាស់ ដែលបានមាលានិងលោកពូផ្តួចផ្តើម
រកការងារឱ្យធ្វើក្នុងក្របខ័ណ្ឌរាជការនៅស្រុកខ្មែរនេះ ប៉ុន្តែសូមមាលា
ផ្អាកទៅវិញចុះ ទុកឱ្យបងបានសួរយោបល់ពីឪពុកម្តាយរបស់បងឯស្រុក
សិន !

ឮសំដីរបស់ខ្ញុំ មាលាស្លាកមុខ ភាពរីករាយរលាយបាត់អស់រលីង
មួយរំពេច ! មួយសន្ទុះ ទើបនាងពោលមួយៗ ដោយស្រងូតស្រងាត់ :

- គំនិតរបស់បងត្រឹមត្រូវណាស់ ! បងត្រូវតែសាកសួរយោបល់

របស់ឪពុកម្ដាយបងនៅឯស្រុកសិន មិនអីទេ ចាំខ្ញុំជំរាបពុកវិញ !..

ខណៈនោះ ក្មេងកុមារមួយហ្វូង ស្លៀកពាក់ស្អាតបាតដើរពីកំពង់ទូកដមក ដែលក្នុងចំណោមនោះមានហ៊ីនប្អូនរបស់មាលាផង ! មកដល់មាត់ទ្វាររបង ហ៊ីនរត់សៀនស្ទេវចូលមកក្នុងវែផ្ការដើងផាក់បងស្រី

- បងអើយ ខ្ញុំទៅមើលកុនរឿងល្អមើលណាស់ !

- រឿងអីទៅ អាអូន ? ( មាលាបែរទឹកមុខរីករាយវិញ )

- គេបញ្ចាំងរឿងសណ្ដាណាបង អូយ ! ខានយក្ស មានទេពស្រី ៗ ល្អមើលណាស់ ! . . .

- អាអូនមើលនៅរោងណា ?

- រោងស្ដីតេដែលនៅជិតវាលមេរុនោះណ៎ា ! បងមាលាមិនចង់ឬជាន់នាំគ្នាទៅមើលទៅ តែខ្ញុំថាល្អមើល គឺល្អហើយ !..

មាលាងាកមកសើចដាក់ខ្ញុំ ហើយនិយាយទៅកាន់ប្អូន ៖

- ឱ្យបាយមានស្រេចអស់ហើយ ទៅដួសហូបខ្លួនឯងចុះ !

ហ៊ីនដោះអាវបណ្ដើរឡើងផ្ទះបណ្ដើរហាក់ដូចឃ្លានណាស់ ។

មាលាឈ្ងោកមុខសម្លឹងអីហើយសួរខ្ញុំ ៖

- ចាំម៉ែមកពីវត្តវិញ ខ្ញុំនឹងសុំគាត់ទៅមើលកុនជាមួយបង ! តើបងព្រមជូនខ្ញុំទៅទេ ?

ខ្ញុំអរព្រួចដូចកូនក្មេងបានស្ករគ្រាប់ ប៉ុន្តែធ្វើជាអះអុញ ៖

- ខ្ញុំចង់ទៅមើលណាស់ ! ប៉ុន្តែបើដើរតែពីរនាក់អីចឹង ក្រែងពុំសមភ្នែកញាតិទេដឹង !



- ចង់អ្នកណាថាអីក៏ថាទៅ ! ចុះសព្វថ្ងៃនេះ យើងចែវទូកទៅលេងតែពីរនាក់ដែរនោះ ម៉េចក៏មិនឃើញអ្នកណាថាអីទៅ !

ល្ងាចថ្ងៃនោះ មាលាសុំម្ដាយទៅមើលកុនបានដូចចិត្តមែន ! យើងទាំងពីរនាក់ស្លៀកពាក់ស្អាតបាត ហើយដើរទន្ទឹមគ្នាយ៉ាងស្និទ្ធស្នាល បើសិនជាអ្នកពុំស្គាល់បានឃើញ គេមុខជាយល់ថា យើងជាគូសង្សារ ឬជាប្ដីប្រពន្ធដែលទើបនឹងរៀបការជាមិនខាន ! . . .

ចេញពីរោងកុនវិញ យើងនាំគ្នាហូបចំណី ហើយបណ្ដើរគ្នាដើរលេងក្នុងស្រទាប់មនុស្សច្រើនកុះករនៅថ្ងៃបុណ្យ ។

លុះដល់មកជិតវត្តភ្នំ មិនដឹងជានឹកឃើញយ៉ាងណា បានជាមាលាងាកមកនិយាយនឹងខ្ញុំ :

- កាលពីបងរកស៊ីលីសែងនៅកំពង់ផែ ខ្ញុំឮបងនិយាយប្រាប់ថាបងសំណាក់នៅវត្តភ្នំ . . . ឥឡូវនេះ ខ្ញុំចង់ស្គាល់កន្លែងដែលបងធ្លាប់សំណាក់នោះណាស់ សូមបងនាំខ្ញុំទៅមើលឲ្យបានស្គាល់ផង ! . .

ខ្ញុំភ្ញាក់ផ្អើលក្ដុក ! ពុទ្ធោអើយ កន្លែងដែលខ្ញុំធ្លាប់ដេកនោះ គឺសំយាបព្រះវិហារ តើឲ្យខ្ញុំនាំនាងទៅមើលយ៉ាងម៉េច ! ឃើញខ្ញុំអេះអុញ មាលាកាន់តែសង្ស័យ :

- ឆាប់ឡើងទៅ ខ្ញុំចង់ឃើញកន្លែងកំសត់របស់បង . . .

ប្រកែកពុំរួច ខ្ញុំក៏បោះជំហាននាំនាងឡើងទៅទាំងផ្អូលចិត្ត [illegible]លាយឡំនឹងការអៀនខ្មាសចំពោះមាលា . . .

ឡើងដល់លើភ្នំ ខ្ញុំចង្អុលប្រាប់កន្លែងដែលខ្ញុំធ្លាប់ដេកគ្មានលាក់

លៀម . . . ម៉ាលាឈរមើលផ្កាផ្កាឈើធំយ៉ាងស្រងូតស្រងាត់ ហើយខ្ញុំសង្កេតឃើញនៅក្នុងរង្វង់ភ្នែកទាំងគូរបស់នាង មានដក់ទឹករលីងរលោង ធ្វើឲ្យខ្ញុំសែនរំជួលចិត្តឥតឧបមា ចំពោះសេចក្ដីស្នេហាស្ម័គ្ររបស់ម៉ាលា ។

បន្ទាប់មកទៀត ខ្ញុំនាំនាងទៅថ្វាយបង្គំព្រះសង្ឃដែលធ្លាប់មានធម៌មេត្តា ធ្លាប់ផ្ដល់មុងកន្ទេលដល់ខ្ញុំ ។ ព្រះសង្ឃបានសាកសួរសុខទុក្ខ និងមូលហេតុដែលបាត់មុខមិនដែលឃើញខ្ញុំមកសំណាក់នៅសំយាបព្រះវិហារដូចមុនទៀត ។ ខ្ញុំក៏ទូលលោកដោយត្រង់ ៗ ប៉ុន្តែលាក់រឿងរ៉ាវជួបនឹងមិត្តចិន្តដែលត្រូវគេដេញចាប់មិនឲ្យលោកជ្រាប ហើយក៏នាំគ្នាថ្វាយបង្គំលាចុះពីកុដិមកវិញ . . .

ពេលដើរមកដល់មុខព្រះវិហារ ម៉ាលាងាកសម្លឹងទៅកន្លែងដែលខ្ញុំបង្ហាញនាងម្ដងទៀត ហើយល្បុគចាប់កដៃខ្ញុំហាក់ទាំងមិនដឹងខ្លួន :

- បងចូផាន់ ! . . . នៅក្នុងលោកនេះ ប្រហែលជាមានមនុស្សតិចណាស់ ដែលជួបសេចក្ដីលំបាកវេទនាគ្រប់បែបយ៉ាងដូចរូបបង ! . .

ខ្ញុំនឹកស្រណោះខ្លួនតាមពាក្យសំដីរបស់នាងដែរ ប៉ុន្តែគៀតពោលពាក្យ :

- មិនមែនតែចឹងទេម៉ាលា នៅលើសកលលោកទាំងមូល វណ្ណៈពលករកំពុងតែត្រូវគេជិះជាន់ ដូច្នេះមានមនុស្សច្រើនណាស់ ដែលជួបនឹងទុក្ខវេទនាមិនមែនតែបងទេ ! . . .

ម៉ាលាងាកមើលមុខខ្ញុំស្ងៀង ព្រោះប្រហែលជាមិនសូវយល់នឹងពាក្យសំដីរបស់ខ្ញុំហើយ ។



បន្ទាប់មក យើងទាំងពីរនាក់ស្ងៀមនិយាយស្ដី ដោយកំពុងតែមានអារម្មណ៍រវើរវាយ រហូតទាល់តែដល់កំពង់ផែដោយមិនដឹងខ្លួន ។

* * *

# ៧

## ដួងចិត្តនវល្លសាប

តាំងពីថ្ងៃនោះមក ដួងចិត្តរបស់ខ្ញុំ និង មាលា ក៏ចត្រជាញ់វិញ ចូលគ្នាកាន់តែល្អក្បិតលើសដើម ។ ផុតកាលរហូតហ៊ានដេញបញ្ចុកចំណីគ្នា ប្រឡែងនៅចំពោះមុខឪពុកម្ដាយផង !...

តាមខ្ញុំដឹងប្រពៃណីខ្មែរតឹងរ៉ឹងណាស់ ! ចំពោះការត្រួតត្រារក្សាកូនស្រី ប៉ុន្តែមីងហៀប និង ពូរ៉ុសថែរជាសំដែងអាការៈរីករាយទៅវិញ ទៅពេលដែលឃើញខ្ញុំ និង មាលាប្រឡែងគ្នា ឬ ក៏ពោលពាក្យផ្ដោះផ្ដង ចំអែចំអន់គ្នាលេង ។

អនុស្សាវរីយ៍ដែលខ្ញុំពុំអាចបំភ្លេចបាន គឺល្ងាចមួយនោះ ពូរ៉ុស មានការរវល់ទៅចូលរួមក្នុងពិធីបុណ្យរបស់បងប្អូនម្នាក់នៅភូមិផ្សៃ គាត់ ក៏ឲ្យខ្ញុំ និង មាលាចេញទូកទៅរាយមងតែពីរនាក់ ។

មាលាចែវកន្សៃ ឯខ្ញុំជាអ្នករាយមង ។ ប្រកបកិច្ចការនេះជាង មួយឆ្នាំមកហើយ ខ្ញុំកាន់តែស្ទាត់ជំនាញខុសពីដំបូងឆ្ងាយណាស់ !.. មាលាសង្កត់ទម្ងន់ខ្លួនទៅលើដងចែវមួយ ។ ហើយសម្លឹងមើលខ្ញុំទម្លាក់ មងទៅក្នុងទឹក ដោយញញឹមពេញចិត្ត ។



លុះរាយរស់ហើយ ខ្ញុំមកចែវទូកម្ដងវិញ ដើម្បីទុកឱកាសឲ្យ មាលាសំណាក់ស្ង ព្រោះយើងត្រូវរស់នៅលើទូកនេះមួយយប់រហូតដល់ភ្លឺ ទើបសាមងដោះត្រីយកទៅលក់ ។

ថ្ងៃជិតលិច ពេលបួបអាហារចំអិនរួចស្រេចបាច់ហើយ ស្រាប់ តែមេឃងងឹត ខ្យល់បក់វិលវល់ ផ្គរពពកខ្មៅរសាត់យ៉ាងទាបសំដៅមក ។ ខ្ញុំទម្លាក់យុថ្កាចុះទៅក្នុងទឹក ព្រោះឃើញមាលារៀបចំស្លុកបាយរួច ហើយ ។ ដោយសាររលកខ្លាំងហោះហត់ ប៉ះទង្គិចចុះក្ដោ ។ ផង យើងទាំងពីរនាក់ចាំត្អូញបរិភោគ យ៉ាងឆ្ងាញ់ដោយនិយាយគ្នាពីនេះពីនោះ ឥតដាច់ ។ ខណៈនោះ ស្រាប់តែស្ងប់ខ្យល់ឈឹង ហើយភ្លៀងបង្អុរ ចុះដូចគេហែកមេឃ ។

ដំបូលទូកចាស់រហែកធ្លុះដោយអន្ទើ ពុំទាន់បានជួសជុល គ្រាន់ តែភ្លៀងធ្លាក់បានបន្តិច ក៏ស្រក់តក់ៗមួយរំពេច ។ តំណក់ទឹកស្រក់ចំ ចានសម្លដែលយើងកំពុងតែទទួលទាន បណ្ដាលឲ្យខ្ទាយទឹកសម្ល ប្រឡាក់ដល់ខ្លួន ។ ដោយដំបូលទូកលិចស្ទើរតែសុសទាំងអស់ គ្មានវិធី បញ្ចៀសស្លុកបាយបាន ខ្ញុំនឹកឃើញវិធីមួយ គឺឱនខ្នងគ្របពីលើចាន រង តំណក់ទឹកភ្លៀងដែលស្រក់កុំឲ្យធ្លាក់ទៅក្នុងចាន ដើម្បីបន្តការបរិភោគត ទៅទៀត ។

ឃើញដូច្នោះ មាលាសើចកាច់កកាច់ស្រង់ ទឹង គំនិតចម្លែកនេះ ព្រមទាំងពោលចំអន់លេង ៖

- ថ្ងៃនេះបងបូផាន់ នេះយកខ្លួនរងទឹកភ្លៀងមិនឲ្យចូលចានសម្ល

ចុះថ្ងៃក្រោយ ប្រហែលជាបងអាចយកខ្លួនបាំងមេឃមិនឲ្យមនុស្សទាំងអស់ទទឹកភ្លៀងទេមើលទៅ !...

- ប៉ុន្តែបងអាចបាំងមេឃ មិនឲ្យមនុស្សទទឹកបានតែម្នាក់គត់ ជននោះគឺរូបមាលាតែម្តង (ខ្ញុំឆ្លើយ ហើយជូតទឹកសម្ពុតធ្វើព្រងើយ) មាលាខ្ទប់មាត់សើច ៖

- និយាយជាមួយបងប្អូនមិនសូវបានចំណេញសោះ !...

- តាមក្បួនរកស៊ី បើមិនបានចំណេញក៏ហ៊ានទៅចុះ កុំឲ្យតែខាតដើម !...

មាលាសើចរលាក់ខ្លួនម្តងទៀត ហើយលូកស្លាបព្រាយកដួសសម្ល ។

ដោយខ្ញុំបង្អោនខ្លួនគេចពីលើចានសម្លស្ងោរមេមាន់ក្រអូប មាលាក៏ត្រូវល្បាកឲ្យខាបដែរ ដើម្បីដួសទឹកសម្លឲ្យបាន ។ ពេលងើបមក មុខនាងក៏ប៉ះនឹងមុខខ្ញុំដោយចៃដន្យ ហើយស្រាប់តែមិនដឹងជាមានកម្លាំងអ្វីបានជាជំរុញឲ្យខ្ញុំហ៊ានរុញច្រមុះទៅស្រូបក្លិនថ្ពាល់ របស់មាលាមួយខ្សឹតយ៉ាងវែង ។

តាំងពីមករស់នៅជាមួយគ្នា ថ្វីបើស្និទ្ធស្នាលយ៉ាងណាក៏ដោយ ក៏យើងទាំងពីរនាក់ពុំដែលប៉ះសាច់គ្នាទៅវិញទៅមកទេ ទើបតែពេលនេះជាលើកដំបូង ។ មាលាទម្លាក់ស្លាបព្រាពីដៃមុខក្រហមច្រឿងៗ បបូរមាត់ញាក់ទទ្រើតដោយការអៀនខ្មាស ។ ចំណែកខ្ញុំវិញក៏ភ័យផងសប្បាយផង បេះដូងលោតខុសចង្វាក់ស្ទើរខ្ទាតចេញពីទ្រូង ។ ខ្ញុំខំសម្លឹងមើលមុខនាងទាំងព្រួយបារម្ភ ព្រោះខ្លាចមាលាខឹងច្រឡោត ។



ពីដំបូងនាងភ្ញាក់ផ្អើលផងអៀនខ្មាសផងខ្លាំង ប៉ុន្តែលុះឃើញមុខព្រួយបារម្ភរបស់ខ្ញុំ ប្រហែលជាមាលាអាណិត បានជានាងឈ្ងោកមុខចុះសើច ហើយនិយាយដោយសំឡេងញ័រៗ ខុសធម្មតា ។

- លើកនេះមិនត្រឹមតែអត់បានចំណេញទេ ថែមទាំងខាតចុងខាតដើមទៀតផង ។

ពេលផុតពីមាត់ នាងលើកផ្តិលហូបទឹក ហើយក្រោកទៅយកក្រណាត់កៅស៊ូមកសៀតបាំងពីក្រោមដំបូលទូក ត្រង់កន្លែងដែលលេចត្រូវពីលើខ្លួនខ្ញុំកុំឲ្យទទឹកតទៅទៀត ទើបថយទៅអង្គុយឆ្ងាយ ។

ឃើញដូច្នោះ ខ្ញុំភ័យតក់ក្តាក់ក្នុងពោះ ៖

- មាលាឈប់ហូបហើយ ?..

- ខ្ញុំឆ្អែតហើយ ... មាលាឆ្លើយទាំងញញឹមពព្រាយ )

- មាលាខឹងខ្ញុំឬ ?...

នាងមិនឆ្លើយ គ្រាន់តែឈ្ងោកមុខគ្រវីក្បាលសើចតិចៗ ខ្ញុំបន្តការបរិភោគពីរបីម៉ាត់ទៀតក៏ឈប់ដែរ ។

បន្ទាប់ពីភ្លៀងរាំង មេឃស្រឡះល្អ អាកាសត្រជាក់គួរមនោរម្យ ។

យប់បន្តិច មាលាមកដណ្តើមចែវពីដៃខ្ញុំ ៖

បងចូលទៅសំរាកចុះ ព្រោះកណ្តាលអធ្រាត្រ បងត្រូវសាមង ហើយ ។ ទុកឲ្យខ្ញុំចែវវិញ !...

ខ្ញុំឥតប្រកែក ហើយដើរចូលទៅក្នុងទូកតាមពាក្យនាង ។ តាមពិតបើសិនជាយើងបោះយុថ្កាបណ្តែតទូកកណ្តាលទន្លេ ហើយសំរាកទាំងពីរ

នាក់ក៏បានដែរ ប៉ុន្តែប្រហែលជាមាលាមិនចង់នៅក្នុងទូកទាំងពីរនាក់ ឬមួយក៏នាងចង់ចែវទូកឃ្លាំមើលខ្លាចចោរលួចឫកក៏មិនដឹង ខ្ញុំពុំអាចយល់ចិត្តនាងបានទេ ។

ខ្ញុំដេកក្នុងទូក ទាញភួយមកដណ្តប់ក្រោមពន្លឺចង្កៀងគោមដែលព្យួរនៅលើដំបូល ។ ខ្ញុំដេកពុំលក់ សម្លឹងទៅមើលវេហាស៍ ផ្កាយរះព្រោងព្រាត ព្រះចន្ទចុះទៀតជះរស្មីពណ៌មាសមកលើផ្ទៃគង្គា ផ្លេក ៗ លោតតាមរលកទន្លេ ។

មាលាស្លៀកសារុងផ្កា ពាក់អាវពណ៌ផ្ទៃមេឃដៃវែងរឹបរាង ជួតក្បាលក្រមា ហើយកន្ទុយសក់ហើរប៉ើងតាមខ្យល់គួរគយគន់ ។ នាងយោលខ្លួនបោះជើងសង្កត់ទម្ងន់ទៅលើដងចែវគាស់ទឹកម្តងមួយ ។ ល្អិតល្អន់ដូចកាយវិការរបស់នារីការីសំដែង។ គន់មើលយូរៗទៅ ខ្ញុំឃើញមាលាកាន់តែស្អាតឡើងៗ ប្រៀបបីដូចទេពធីតាចុះចាកពីសួគ៌ា មករេរាំលើផ្ទៃទន្លេសាប ។

ឱផ្កាចន្ទអើយ ! ឱទឹកទន្លេអើយ ! តើអ្នកដឹងឬទេ ថាបេះដូងដ៏បរិសុទ្ធរបស់ខ្ញុំ កំពុងតែត្រូវរបួសជាទម្ងន់ដោយសារព្រួញស្នេហ៍ ។ គឺជាសេចក្តីស្នេហាលើកដំបូងបំផុតក្នុងឆាកជីវិតរបស់ខ្ញុំ ។ ប៉ុន្តែនៅពេលដែលដំណើរជីវិតជួបប្រទះនឹងនារីកំពូលដួងចិត្តនោះ យុវវ័យរបស់ខ្ញុំក៏ត្រូវជួបនឹងផ្លូវបែកជាពីរដែរ ។

ផ្លូវទីមួយ គឺការតស៊ូបដិវត្តរំដោះប្រទេសជាតិពីនឹមអាណានិគមនិយមបារាំង ផ្លូវទីពីរគឺស្នេហា ជាចំណងស្នេហ៍ដែលជំពាក់វណ្ណ



ក្រសោបបេះដូងរបស់ខ្ញុំ រកស្រាយពុំរួចសោះ ។ ទ្រាំពុំបាននឹងទឹកចិត្តរំភើបរំជើបរំជួលនេះ ខ្ញុំក៏ទាញសៀវភៅ និងខ្មៅដៃមកសរសេរ ។

មាលាលួចសង្កេតអាកប្បកិរិយារបស់ខ្ញុំគ្រប់ពេលវេលា ឃើញដូច្នោះនាងស្រែកសួរពីក្រៅ :

- ហេតុអីបងមិនសំរាន្តទៅ ? . . .

- បងដេកស្រួល ទុកឲ្យអូនចែវទូកម្នាក់ឯងអីចឹង វាពុំសមសោះ !

- មានរឿងអីមិនសម . ព្រោះដល់ពេលបងស្រាវបង ខ្ញុំសំរាកខ្លួនវិញទេតើ ! . . . បងសរសេរស្អីហ្នឹង ?

ខ្ញុំមិនឆ្លើយតប តែចាប់ផ្តើមសញ្ជឹងគិតតែងកំណាព្យ ។ ខ្ញុំជាមនុស្សមាននិស្ស័យខាងអក្សរសាស្ត្រ តាំងពីនៅរៀនថ្នាក់បឋមសិក្សារហូតដល់មធ្យមសិក្សា មុខវិជ្ជាតែងសេចក្តី និងកំណាព្យរបស់ខ្ញុំ តែងតែបានទទួលពិន្ទុលេខមួយ ឬលេខពីរជានិច្ច ។

ខ្ញុំសរសេរបណ្តើរគិតបណ្តើរ ជួនកាលខាំចុងខ្មៅដៃត្រិះរិះដោយស្ងៀមស្ងាត់ ។ ឃើញដូច្នេះ មាលាលែងហ៊ានសាកសួរនាំខាន ប៉ុន្តែនាងចេះតែសម្លឹងមើលមកខ្ញុំដោយចម្លែកក្នុងចិត្តជាខ្លាំង លុះសរសេរចប់ ខ្ញុំផ្អាក់ខ្មៅដៃចុះ ហើយក្រោកអង្គុយអានកំណាព្យសាឡើងវិញដោយញញឹមពេញចិត្តម្នាក់ឯង ។

- ឃើញដូច្នោះ មាលាទប់ទល់នឹងការងឿងឆ្ងល់លែងបាន ក៏លើកចែវដាក់តង់លើទូក បណ្តោយទូកឲ្យរសាត់តាមខ្សែទឹកស្រេចនឹងចិត្ត ហើយរត់ចូលមកក្នុងពោលរំអុក *

- ឲ្យខ្ញុំសុំមើលផង បងសរសេរស្អីហ្នឹង ! ប្រហែលជាបងសរសេរសំបុត្រស្នេហាទៅនារីណាម្នាក់ហើយមើល៍ទៅ មាត់និយាយ តែដៃលូកឆក់យកសៀវភៅពីខ្ញុំ )

- មិនមែនជាសំបុត្រស្នេហាទេ គឺបងតែងកំណាព្យលេងទេតើ ( ខ្ញុំនិយាយទាំងសើច ហើយបណ្ដោយឲ្យនាងលាយកទៅកាន់ ) ។

តាមការពិត ពេលនេះភ្លេចខ្លួនថាខ្ញុំឥតចេះអក្សរខ្មែរទេ ឯរូបនាងក៏ឥតចេះអក្សរឡាវដែរ ចេះតែភាសានិយាយប៉ុណ្ណោះ ។ ជួរច្នេះរវាងនាង និងខ្ញុំគឺមួយជំហនិងប្អូន ។ ទៅក្នុងពេញជិតពីរឆ្នាំនេះ ខ្ញុំចេះនិយាយភាសាខ្មែរច្រើនល្មមប្រើការបាន ។ យើងទាំងពីរនាក់រស់នៅជាមួយគ្នា ជួននិយាយឡាវ ជួននិយាយខ្មែរតាមតែចិត្តឃើញ ប៉ុន្តែបើទាងសរសេរ-អក្សរខ្មែរ ខ្ញុំឥតចេះមានទេ ហើយបើខ្ញុំសរសេរភាសាឡាវវិញ ក៏នាងអានពុំកើតដែរ ។

បន្ទាប់ពីឃើញអត្ថបទជាភាសាឡាវ មាណាគក់ខ្ញុំមួយដៃដោយគ្នាន់ខ្នាញ់ ព្រមទាំងហុចសៀវភៅឲ្យវិញ ។

- បងអានឲ្យខ្ញុំស្ដាប់ភ្លាមមក៏ !

- មិនអីទេ មាណាចាំស្ដាប់ណ៎ា !

ខ្ញុំក៏ចាប់ផ្ដើមអានកំណាព្យឲ្យនាងស្ដាប់តាំងពីដើមដល់ចប់ ។ ប៉ុន្តែស្ដាប់រួចហើយ នាងស្រញូចចិញ្ចើមសញ្ជឹងគិតធ្វើភ្នែកព្រិច ៗ ហើយញញឹមស្ញឹកគ្រវៀកខ្ញុំ ពោលថ្លុកថ្លក់ :

- បងឯងខូចណាស់តើ ប៉ុន្តែ សូវយល់ទេ បងត្រូវអានម្ដងទៀត



ហើយអានឲ្យយឺត ៗ កុំលឿនពេក !

- ខ្ញុំគិតក្នុងចិត្តតែម្នាក់ឯងថា តាមការពិតមាណាមិនមែនស្ដាប់ពុំទាន់ទេ ប៉ុន្តែមកពីនាងពុំយល់ដល់ន័យរបស់ពាក្យពេចន៍អក្សរសាស្ត្រក្នុងអត្ថបទ ។

ដឹងដូច្នេះ ខ្ញុំក៏អានយឺត ៗ មួយឃ្លាម្ដង ៗ ពាក្យណាពិបាកខ្ញុំពន្យល់នាងទាល់តែយល់ ជួនជាភាសាខ្មែរ ជួនជាភាសាឡាវ ហើយមានពេលខ្លះ នាងក៏ជជីកសួរបញ្ជាក់ខ្លួនឯងទៀត ។

អត្ថបទកំណាព្យ មានខ្លឹមសារថា :

- ជុំនោររាត្រី លើផ្ទៃគង្គា សែនរងាញាប់ ញ័រក្នុងកាយា
នៅលើទូកតូច ឃើញផ្ទាល់នេត្រា ទេពធីតាដែល ចុះចាកសួគ៌ា ។
- រូបកាយនាងនាថ ស្អាតផុតលោកិយ ចិត្តកវីត្រូវ រលួសត្រាំត្រា
ខ្ទាត់ព្រឹព្រួច ក្ដួចតាប់ទយា ទ្រូងកំព្រាត្រូវជាប់ ដោយព្រួញស្នេហ៍ ។
- គេសាអន្លាយ រំសាយសែនស្រស់ គង់ឥតខ្ចោះ ល្អបីដូចដួងខែ
ទន្លេសាប សម្បត្តិជាតិខ្មែរ ជួយបកប្រែផង ពាក្យពេចន៍ភាសា ។
- ខ្ញុំស្ម័គ្រនាងស្មោះ អស់ពីដួងចិត្ត អ្នកអាណិតជួយ ឲ្យប្រាប់នាងថា
បើខ្ញុំពុំបាន ជួបដួងច័ន្ទថ្លា ក្ស័យសង្ខារពិត ដូចនាងកន្ត្រើ ។
- ប៉ុន្តែច័ន្ទអើយ អ្នកនៅសែនខ្ពស់ ខ្ញុំជាមនុស្សរស់ នៅលើផែនដី
គ្មានញាតិគ្រួសារ គ្មានធនធានអ្វី តែភក្ដីភាព បរិសុទ្ធពិត ។
- ប្រសិនបើខ្ញុំ មានភ័ព្វវាសនា បានសច្ចាផ្សង តាំងពីព្រេងព្រឹទ្ធ
សូមចន្ទរះភ្លឺ កុំបាំងងងឹត ស្ពាងជីវិតខ្ញុំ គ្មានលុះអវសាន ។

ក្រោយពីស្ដាប់យល់ខ្លឹមសារសព្វគ្រប់អស់ហើយ មាលាបើកភ្នែកខ្មៅយង់សម្លឹងមុខខ្ញុំ ហើយសួរទាំងសើចក្អឹក ៖

- ទេពធីតារបស់បងនោះនៅឯណា ? . .
- ទេពធីតាចុះពីស្ថានព្រះចន្ទ គឺនាងជាកូនក្រមុំរបស់ព្រះចន្ទ ! . .
- ហាស ៗ . . ខ្ញុំមិនដែលឮថា ព្រះចន្ទមានកូនសោះ . . .
- មាលាមិនដឹង បានជាខ្ញុំប្រាប់ គឺនាងជាព្រះចន្ទដែលរះនៅក្នុងដួងចិត្តខ្ញុំ ! . .
- ទេពធីតានោះ នៅឯណាទៅ ប្រាប់ខ្ញុំផងមើល ! . .
- នៅចំពោះមុខហ្នឹងផង ( ខ្ញុំនិយាយព្រមទាំងចង្អុលនាង )

ឮដូច្នោះ មាលាក្ដាប់ដៃគក់ស្មាខ្ញុំ ៖

- បងបូជាត់ឥឡូវនិយាយលេងណាស់ ! . .

ខ្ញុំសើចហើយដើរចេញទៅក្រៅ ចាប់ផងចែវវាតបក់ក្បាលទូកចែវបញ្ច្រាសទៅទើកឡើងមកវិញ ព្រោះកុំឱ្យទូកសាត់ទៅឆ្ងាយពេក ។

មាលាអង្គុយត្រដាងសៀវភៅមើល ក្រោមពន្លឺចង្កៀងហាក់ដូចជានាងចេះអានអីចឹង ។ មួយសន្ទុះមើលខាងចុងសៀវភៅ ហើយសៀតថ្នម ៗ ទៅនឹងផ្កាវៃទូក រួចពោលមកកាន់ខ្ញុំ ៖

- ខ្ញុំមិនស្មានថា បងជាកវីសោះ ! . . កំណាព្យនេះ បងត្រូវទុកឱ្យខ្ញុំណ៎ា ! . .

យប់កាន់តែជ្រៅ ដួងច័ន្ទនៅតែគង់បាញ់ភ្លឺផ្អែមទន់ស្រាលដដែល គ្មានពពកខ្មៅ មកបិទបាំងបន្តិចសោះ ។ សន្សើមរាត្រីក៏ស្រក់ចុះរោយរាយ



ប្រៀបបីដូចទឹកមន្តស្នេហ៍ស្រោច ស្រពមកលើបេះដូងក្រមុំបរិសុទ្ធរបស់យើងទាំងពីរនាក់ ឱ្យលិចលង់ទៅក្នុងពិភពស្រមៃមួយដែលពោរពេញទៅដោយសេចក្ដីសង្ឃឹមលើវាសនាអនាគតរបស់ខ្លួន ។

រាត្រីនោះហើយ ដែលខ្ញុំសម្រេចចិត្តថា នឹង ត្រឡប់ទៅស្រុកកំណើតវិញ ដើម្បីជួបឪពុកម្ដាយបងប្អូន នឹង វិលត្រឡប់មកវិញ ចូលស្ដីដណ្ដឹងយកនាងមាលាធ្វើជាគូគាប់វាសនារហូតអស់មួយជីវិត ។

* *

*

# ៨

## អនុស្រពាត់គ្នា

ប៉ុន្មានថ្ងៃក្រោយមកទៀត ខ្ញុំក៏ជំរាបពូរ៉ុសនិងមីងហែមសុំលាត្រឡប់ទៅស្រុកកំណើតមួយគ្រាសិន ។ ម្ចាស់ផ្ទះទាំងពីរនាក់ប្ដីប្រពន្ធគត់ឃាត់ឃាំងអ្វីទេ គ្រាន់តែផ្ដែផ្ដាំឲ្យខ្ញុំឆាប់វិលត្រឡប់មកវិញកុំទៅយូរពេក។ លើសពីនេះមីងហែមបានទិញក្រណាត់និងសំលៀកបំពាក់ល្អ ។ ផ្ញើទៅជូនឪពុកម្ដាយខ្ញុំមានទាំងត្រីងៀតនិងប្រហុកមួយចំនួនធំផង ។ ឯប្រាក់កាសដែលគាត់ផ្ដល់ឲ្យខ្ញុំ ក៏គ្រប់គ្រាន់ចាយវាយក្នុងការធ្វើដំណើរទាំងទៅទាំងមក ពុំព្រួយបារម្ភដល់ការខ្វះខាតទេ ។

រៀបចំស្រេចបាច់ ខ្ញុំសំពះលាជនសប្បុរសទាំងពីរ ចុះទូកឆ្លងទៅភ្នំពេញ ដើម្បីឡើងកប៉ាល់ធ្វើដំណើរទៅខេត្តស្ទឹងត្រែង ព្រោះទៅដល់ខេត្តនោះ ខ្ញុំអាចធ្វើដំណើរឆ្លងត្រើយចូលទឹកដីប្រទេសឡាវ ។

ពូរ៉ុស និងមីងហែម បានឲ្យពរសព្ទសាធុការ និង សំដែងសេចក្ដីអាឡោះអាល័យចំពោះខ្ញុំ ប្រៀបដូចឪពុកម្ដាយអាណិតស្រណោះចំពោះកូន ដែលឃ្លាតទៅឆ្ងាយអស់ពេលដ៏យូរតើចឹង ។

កប៉ាល់ដែលដឹកនាំអ្នកដំណើរពីភ្នំពេញទៅស្ទឹងត្រែង ត្រូវចេញពី



កំពង់ផែនៅម៉ោងប្រាំល្ងាច ប៉ុន្តែមាលាបានបបួលហិនចែវទូកជូនខ្ញុំទៅតាំងពីម៉ោងពីររសៀលម្ល៉េះ ។ ខ្ញុំយល់ស្រេចទៅហើយតាមការគិត មិនមែនមាលាខ្លាចខ្ញុំខកដំណើរទៅពុំទាន់ជិះកប៉ាល់នោះទេ ប៉ុន្តែចិត្តរបស់នាងក៏ដូចខ្ញុំដែរ គឺយើងចង់ទាញយកពេលវេលាសំណេះសំណាលគ្នាស្ងាត់ៗតែពីរនាក់ជាចុងក្រោយឲ្យបានយូរ ។

ទៅដល់ផែ ក្រោយពីទិញសំបុត្រកប៉ាល់រួចហើយ មាលានិយាយទៅកាន់ប្អូនប្រុស :

- នៅប្រហែលពីរម៉ោងទៀតទើបកប៉ាល់ចេញ ហិន ! ប្អូនឯងនៅចាំទូកបងនិងបងបូផាន់ ឡើងទៅផ្សាររកទិញរបស់របរខ្លះថែមទៀតណ៎ា !

ហិនសើចស្ញាញងក់ក្បាល :

- មកវិញបងទិញនំប៉័ងដាក់សាច់ផ្ញើខ្ញុំផង ! . . .
- ចាំបងទិញផ្ញើ . . . ( ខ្ញុំឆ្លើយជំនួសមាលា )

តាំងពីកំពង់ផែមកដល់ភ្នំ យើងដើរទន្ទឹមគ្នាមែន ប៉ុន្តែឥតស្ដីនិយាយមួយម៉ាត់សោះ ព្រោះហាក់ដូចជាមានវត្ថុអ្វីមួយមកស្ទង់បំពង់កនិយាយពុំចេញ ។ ស្ងៀមស្ងាត់មែន ប៉ុន្តែភ្នែករបស់យើងទាំងពីរសម្លឹងមុខគ្នាទៅវិញទៅមក បង្ហាញនូវសេចក្ដីអាឡោះអាល័យច្បាស់ក្រៃលែង ។

លុះឡើងដល់លើភ្នំ មាលាដើរចូលទៅក្នុងព្រះវិហារ លុតជង្គង់ពីមុខព្រះពុទ្ធបដិមាករដុតធូបបីសរសៃ ហើយផ្គងដៃសំពះបន់ស្រន់ ៖

- សូមគុណបុណ្យព្រះរតនត្រ័យនិងវត្ថុស័ក្ដិសិទ្ធិនានានៅក្នុងលោក

ជួយបីបាច់ថែរក្សាបងប្អូនផង ឲ្យធ្វើដំណើរបានប្រកបដោយសេចក្ដីសុខសប្បាយរហូតទៅដល់ស្រុកកំណើតរបស់គាត់ និង បានវិលត្រឡប់មកវិញដូចពាក្យសន្យា ។

បើពីថ្ងៃមុនៗ ឃើញមាលាដុតធូបបន់ព្រះអីចឹង ខ្ញុំច្បាស់ជានិយាយបន្ដាប់ចំអន់ចំពោះជំនឿអរូបិយរបស់នាងជាមិនខាន ។ ប៉ុន្តែពេលនេះ ខ្ញុំពុំអាចនិយាយលេងសើចបានទេ ផ្ទុយទៅវិញគ្រាន់តែអាណិតមាលាថែមទៀត ព្រោះយល់ថា អំពើរបស់នាងនេះ គឺផុសចេញមកពីការស្រឡាញ់ខ្ញុំពេក។

ខ្ញុំឈរមើលកាយវិការនិង ទឹកមុខស្រពាប់ស្រពោនរបស់នារីកំពូលដួងចិត្ត ដោយក្ដីខ្លោចផ្សា ស្ទើរតែប្ដូរចិត្តលែងចង់ធ្វើដំណើរទៅស្រុកវិញ ។ ប៉ុន្តែពេលនោះ ខ្ញុំភ្ញាក់ស្មារតីទប់ទល់ចិត្តឲ្យរឹងប៉ឹងវិញ ព្រោះគិតថា ការធ្វើដំណើរទៅស្រុកនេះ ក៏ដើម្បីជំរាបឪពុកម្ដាយឲ្យគាត់ជ្រាបនិងវិលមកស្ដីដណ្ដឹងមាលាវិញដែរ ។

បន់ស្រន់ចប់ មាលាងាកមើលមុខខ្ញុំទាំងរលីងរលោងទឹកភ្នែក ។ ដើម្បីបន្ធូរទឹកចិត្តរំភើបរំជួលដែលកំពុងតែពុះកញ្ជ្រោលនោះ ខ្ញុំដើរចូលទៅលុតជង្គង់ទន្ទឹមនឹងនាង ហើយដុតធូបបីសរសៃដោយពោលខ្សឹបៗ ល្មមតែឮពីរនាក់ ៖

- សូមគុណបុណ្យព្រះរតនត្រ័យ ជួយបីបាច់ថែរក្សាអូនមាលាឲ្យបានប្រកបតែនឹងសេចក្ដីសុខគ្រប់ពេលវេលា . . .

នេះជាលើកដំបូងបង្អស់ ដែលខ្ញុំប្រើពាក្យ " អូន " ចំពោះមាលា ធ្វើឲ្យនាងញេញាកមុខញញឹមស្ញៀនស្ញើន ប៉ុន្តែលុះយូរទៅ ស្នាម



ញញឹមរបស់នាងស្រាប់តែលេចចេញនូវភាពស្រពោះស្រពោនខ្លោចផ្សាទៅវិញ ។ តាមខ្ញុំកាត់យល់ ប្រហែលជាមាលាគិតឃើញថា រហូតមុនពេលបែកគ្នា ទើបនាងបានឮពាក្យនេះចេញពីមាត់ខ្ញុំ . . . ។

បន្ទាប់មក ខ្ញុំទាញដៃមាលាឲ្យក្រោកឈរជាមួយគ្នា នាងឥតសំដែងអាការៈភ្ញាក់ផ្អើល ឬក៏រើបម្រះបន្តិចសោះ ហាក់ដូចជាពេលនេះ នាងលែងគិតគូរដល់ការប៉ះពាល់សាច់ឈាមរវាងក្រមុំ និងកំលោះហើយ ។

ខ្ញុំនាំនាងដើរចុះពីវត្តភ្នំ ហើយនិយាយគ្នាឥតឈប់ មាត់តែនិយាយ ជើងចេះតែបោះជំហានទៅមុខ រីឯពាក្យពេចន៍វិញ គ្មានអ្វីក្រៅពីការរៀបរាប់ថ្លែងពីទុក្ខក្រៀមក្រំ និងការនឹករលឹកទៅវិញទៅមក ក្នុងពេលបែកគ្នាតែប៉ុណ្ណោះ ។ មិនយូរប៉ុន្មាន យើងមកដល់រូបពីរ ដោយមិនដឹងខ្លួន ឃើញផ្ទះ មាលាផ្ដើមរំលឹក ៖

- យើងដូចជាមកឆ្ងាយពីកំពង់ផែពេកហើយបងប្អូនផង !

ខ្ញុំងក់ក្បាល ហើយទាញដៃនាងទៅអង្គុយលើខឿន ក្រោមរូបចម្លាក់ ៖

- សំរាកបន្តិចសិន សឹមត្រឡប់ទៅវិញ . . .

រសៀលទន់ទាបបន្តិចទៅហើយ ធាតុអាកាសចាប់ផ្ដើមបន្ធូរកំដៅ ខ្យល់បក់ល្ហៀកៗ សកម្មភាពចរាចរតាមវិថីនានាហាក់អ៊ូអរជាងពេលថ្ងៃ ប៉ុន្តែដួងចិត្តរបស់ខ្ញុំ បែរជាអណ្ដែតអណ្ដូងទៅក្នុងភាពព្រួយធំត្រមោច កាន់តែខ្លាំងទៅវិញ ។

អង្គុយស្ងៀមស្ងាត់អស់មួយសន្ទុះ ខ្ញុំនឹកកាត់ចិត្តខ្លាចរអាដែលធ្លាប់

បានតាំងពីយូរមកហើយនោះ ហើយពោលទៅកាន់មាលាដោយសំឡេងញាប់ញ័រខុសធម្មតា ៖

- អូនមាលា !..

- ចាំ !.. ( នាងឆ្លើយទាំងងាកមើលមុខខ្ញុំ )

- មុននឹងបែកគ្នា បងចង់បកស្រាយទឹកចិត្តពិតរបស់បងប្រាប់អូន...

ពេលនេះ ស្រាប់តែខ្ញុំមានសេចក្ដីក្លាហានយ៉ាងចម្លែក ហ៊ាននិយាយពាក្យអូនបងជាមួយមាលាពេញមាត់ ។ មាលាឈ្ងោកមុខសម្លឹងដីដោយក្ដីអៀនខ្មាស និង រំភើបភ្ញាក់ផ្អើល ហាក់ដូចនាងកាត់យល់មុនពីពាក្យពេចន៍ដែលខ្ញុំត្រូវនិយាយនៅពេលនេះរួចទៅហើយ ។ នាងញីជាយអាវ ហើយស្ទើរតែមិនចេញសំឡេង ៖

- បងមានការពិតអីទៅ !..

- បងស្រឡាញ់អូន .. ស្រឡាញ់ជាយូរមកហើយ ( នេះជាលើកដំបូងបង្អស់ ដែលខ្ញុំហ៊ានបើកកកាយសេចក្ដីស្នេហាប្រាប់នាង )

មាលាមានទឹកមុខកាន់តែក្រហមដោយសេចក្ដីអៀនខ្មាស ហើយឈ្ងោកកាន់តែទាប ។ បន្ទាប់ពីសញ្ជឹងគិតបន្តិច ស្រាប់តែនាងខំសម្រួលអាកប្បកិរិយាសើចទឹក ។ ហាក់ដូចគ្មានរឿងអ្វីកើតឡើងសោះ ហើយតបមកវិញ ៖

- ខ្ញុំក៏បានដឹងដែរថា បងស្រឡាញ់ខ្ញុំ ... ស្រឡាញ់ដូចប្អូនស្រីរបស់បងបង្កើតអីចឹង !..



ព្រោះរយៈកាលដែលយើងរស់នៅជាមួយគ្នាជាងមួយឆ្នាំកន្លងមកនេះ បងល្អនឹងខ្ញុំណាស់ ពុំដែលធ្វើឲ្យប្អូនស្រីឈឺសចិត្តពីរឿងអ្វីមួយទេ !..

ខ្ញុំទឹកហួសចិត្តនឹងពាក្យសំដីក្រមាច់ក្រមើមរបស់មាលា ព្រោះដឹងថានាងនិយាយធ្វើតេះតែបែបនេះ ដើម្បីបង្ខំសេចក្ដីអៀនខ្មាស នៅពេលដែលបានឮពាក្យពេចន៍ស្នេហាជាគ្រាដំបូង ក្នុងយុវវ័យរបស់នាង ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ទឹកមុខក្រហមដូចផ្លែបាសទុំរបស់នាង ពុំអាចលាក់បាំងការពិតក្នុងចិត្តនាងបានឡើយ ។

ខ្ញុំនៅតែព្យាយាមទាញការសន្ទនា បំបែរចូលបកមកមនោសញ្ចេតនាវិញ ៖

- កាលណាទៅដល់ស្រុក ខ្ញុំនឹងអញ្ជើញពុកម៉ែព្រមទាំងញាតិគ្រួសារទាំងអស់មករស់នៅឯស្រុកខ្មែរនេះ រួចហើយ ខ្ញុំនឹងខំរកស៊ីសន្សំប្រាក់ដើម្បីចូលស្ដីដណ្ដឹងមាលាតាមប្រពៃណី ... តើអូនថាម៉េចដែរ ?

ឮពាក្យសំដីម៉ឺងម៉ាត់ និង ស្មោះត្រង់របស់ខ្ញុំ មាលាប្រែទឹកមុខភ្លាម ។ អាកប្បកិរិយាក្រមាច់ក្រមើមរបស់នាងក៏រលាយបាត់អស់ទៅវិញមួយរំពេច ។ ឃើញនាងស្ងៀមស្ងាត់យូរពេក ខ្ញុំសង្កើញសួរបញ្ជាក់ ៖

- ម៉េចបានជាអូនមិនឆ្លើយ !.. មាលាខឹងនឹងសំដីរបស់ខ្ញុំឬ ?..

នារីក៏ក្ដួលផ្លូវចិត្តនៅតែឈ្ងោកសម្លឹងដី ញីជាយអាវតែរចេញរាចាដដែល ។ ខ្ញុំលូកដៃញែកសក់នាងផាត់យកក្រោយទាំងញ័រទ្រើត ដើម្បីមើលមុខនាងចង់ដឹង ហើយប្រែសំនួរ ៖

- អូនព្រមរៀបការជាមួយបងទេ ?

- មាលាងក់ក្បាល ប៉ុន្តែឥតចេញស្តី ។ ពេលនេះ ខ្ញុំសំគាល់ឃើញមាលាប្រៀបដូចជាកុមារីម្នាក់ ដែលកំពុងតែញាប់ញ័រដោយការភ័យខ្លាចគួរឲ្យអាណិតអាសូរជាទីបំផុត ។

ជាងមួយឆ្នាំកន្លងមកហើយ ដែលយើងរស់នៅក្រោមដំបូលផ្ទះជាមួយគ្នាយ៉ាងជិតស្និទ្ធ ។ មាលាធ្លាប់តែនិយាយលេង ចំអែចំអន់ខ្ញុំជារឿយៗ ដឹងអីពេលនេះ នាងសំដែងអាការៈដូចមនុស្សទើបនឹងស្គាល់គ្នាជាលើកដំបូង ថែមទាំងមិនហ៊ានងើបមើលមុខខ្ញុំផង ។ មាលាមិនឆ្លើយមែន ប៉ុន្តែការងក់ក្បាលយល់ព្រមរបស់នាង មានអត្ថន័យជ្រៅជ្រះលើសពាក្យពេចន៍សារភាពទទួលរាប់រយផងទៅទៀត ។

ខ្ញុំសែនរំភើបត្រេកអរក្រៃលែង ទទួលអារម្មណ៍ហាក់ដូចបេះដូងរឹតលោតខុសធម្មតា ហើយឈាមក៏ដើរខុសចង្វាក់ដែរ ។ ស្ងាត់នៅក្នុងភាពអៀនខ្មាសអស់ពេលយ៉ាងយូរ ទើបមាលានាំប្រមូលសេចក្តីក្លាហានងើបមុខពោល ៖

- សូមឲ្យពាក្យសំដីរបស់បងនៅថ្ងៃនេះ សុទ្ធតែជាពាក្យពិតទាំងអស់ទៅចុះ . . .

មាលានិយាយតិចមែន ប៉ុន្តែមានខ្លឹមសារទូលាយណាស់ ។ ខ្ញុំពុំទាន់រកពាក្យឆ្លើយតបបានផង នាងបើកកាបូបដករូបថតរបស់នាងមួយសន្លឹកទំហំប៉ុនបាតដៃហុចឲ្យខ្ញុំ ៖

- នេះណ៎ះ មានរូបថតរបស់បងហើយ កាលណាខ្ញុំនឹកបង ខ្ញុំមើល



រូបថត ។ ចំណែកបងគ្មានរូបថតរបស់ខ្ញុំតាមខ្លួនទេ ។ នេះ បងយកមួយសន្លឹកចុះ ហើយសូមបងឆាប់ត្រឡប់មករកម្ចាស់រូបថតវិញណា . . .

ពេលបានត្រឹមណោះ មាលាអួលដើមកនិយាយលែងចេញ មិនដឹងជានាងអៀនខ្មាសឬក៏នឹកស្រណោះពេក ។ ខ្ញុំទទួលរូបថតពីសង្សារយកមកមើលយ៉ាងយូរ ទើបដាក់ទៅក្នុងហោប៉ៅអាវទាំងក្តុកក្តួលក្នុងចិត្ត ។

កប៉ាល់បន្លឺសញ្ញាជាច្រើនលើកច្រើនសា ទើបចាកចេញពីកំពង់ផែភ្នំពេញ ។ មាលានិងម៉ែនៅអង្គុយក្នុងទូក តាមមើលនាវាដឹកអ្នកដំណើរនេះឥតក្រឡេកទៅណាសោះ ។ លុះកប៉ាល់ឃ្លាតទៅកាន់តែឆ្ងាយណាស់ហើយ ខ្ញុំឃើញមាលាឈ្ងោកមុខយំ ។

ព្រះសុរិយាលិចស្រើមទៅក្នុងជម្រៅជើងមេឃទិសខាងលិច ។ ទឹកទន្លេមានរលកតូចៗ រត់ប្រជែងគ្នា ហាក់ដូចផ្គួតផ្គងកំពុងប្រមូលផ្តុំនូវក្តីទុក្ខកង្វល់និងភាពស្រងេះស្រងោច មកក្រសោបបេះដូងខ្ញុំឲ្យកាន់តែខ្លោចផ្សាឡើង ។

* *

*

# ៩

## ប្រែប្រួល

ភូមិកំណើតរបស់ខ្ញុំ ត្រូវខ្ទេចខ្ទីដោយសារគ្រាប់បែករបស់ពួកថៃ ស្ទើរមើលពុំស្គាល់ ។ ផ្ទះដែលខ្ញុំធ្លាប់ជ្រកកោនរស់នៅតាំងពីក្មេងកាន់តែទ្រុឌទ្រោម ហើយមានជញ្ជាំងមួយចំហៀងត្រូវរុំព័ទ្ធដោយស្លឹកខ្ចៅ ។

ម្ដាយរបស់ខ្ញុំចាស់ជរាជាងពីមុនច្រើនណាស់ ស្បែកមុខរបស់គាត់ជ្រីវជ្រួញ សក់ចាប់ផ្ដើមស្កូវល្វាយអាចម៍ខ្លាហើយ ។ គ្រាន់តែជួបមុខខ្ញុំភ្លាម ម៉ែនបក្ខចេញហៅរៀបរាប់ដោយក្ដីទឹកភ្នែក និង ការរស់នៅប្រកបដោយទុក្ខសោកផ្ទាល់របស់គ្រួសារខ្ញុំ ក្នុងរយៈកាលប៉ុន្មានឆ្នាំកន្លងមកនេះ ហេតុខ្ញុំក៏ពុំអាចទប់ទឹកភ្នែកពុំឲ្យស្រក់ចុះបានដែរ ។ ម៉ែផឹកស្វាគតឈប់ អំពីការសោកអណ្ដែតយ៉ាងក៏សត់អបរបស់ខ្ញុំ ចាប់ពីត្រូវពួកជាវាំងចាប់យកទៅ ។ ខ្ញុំរៀបរាប់ជំរាបអ្នកមានគុណហួសហេតុទាំងអស់ ។

ពេលស្ដាប់ផល់រឿងដែលគ្រួសារញញឹសស្រឡាញ់រាប់អានជួយចិញ្ចឹម និងផ្គត់ផ្គង់ទំនុកបំរុងរូបខ្ញុំ ម៉ែលើកដៃសំពះឡើងទៅលើថ្លែងអំណរគុណចំពោះទេវតា ដែលបានប្រោសប្រណីផ្ដល់សេចក្ដីសុខ និង ជួយថែ



រក្សាខ្ញុំ ។ ខ្ញុំមានគំនិតមិនស្របនឹងអ្នកម្ដាយសោះ ព្រោះតាមការពិតអ្នកដែលជួយចិញ្ចឹមផ្គត់ផ្គង់ខ្ញុំគឺជាគ្រួសារខ្មែរមួយ មិនមែនឥន្ទព្រហ្មទេវតាឯណាទេ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនហ៊ានពោលពាក្យអ្វីប្រឆាំងនឹងម៉ែដែរ ។

រឿងដែលធ្វើឲ្យខ្ញុំកាន់តែខ្លោចផ្សាចំពោះម៉ែកាន់តែខ្លាំងទៅទៀតគឺសព្វថ្ងៃនេះ ម៉ែរស់នៅជាមួយ នឹង ប្អូនស្រីរបស់ខ្ញុំម្នាក់ឈ្មោះ ខែម ផន ដែលទើបនឹងមានអាយុដប់ឆ្នាំប៉ុណ្ណោះ ។ រីឯឪពុកខ្ញុំ បងប្រុសខ្ញុំម្នាក់ និង ប្អូនប្រុសពីរនាក់ទៀត បាននាំគ្នាចូលព្រៃ ធ្វើការតស៊ូក្នុងចលនាតស៊ូរ ដើម្បីរំដោះប្រទេសជាតិទាំងអស់ ។ ខែមផន ជួបខ្ញុំលើកដំបូងរាតតស្គាល់ខ្ញុំទេ ព្រោះខ្ញុំបែកពីគ្រួសារតាំងពីប្អូនស្រីនេះនៅតូចម្ល៉េះ ។ ឃើញប្អូនរបស់ខ្លួន ខ្ញុំនឹកដល់ហៅប្អូនរបស់មាលា ហើយក៏នឹកដល់ពាក្យបណ្ដាំរបស់សង្សារគេគ្រូចដែរ ។

ក្រោយពីជួសជុលផ្ទះសំបែង និង នៅធ្វើការបំរើម្ដាយបានគន្លះខែ ខ្ញុំក៏សាកល្បងបបួលគាត់មករស់នៅទីក្រុងភ្នំពេញ ដោយពន្យល់គាត់ថា នៅស្រុកខ្មែរ ខ្ញុំអាចកសាងជីវភាពគ្រួសារឲ្យបានធូរធារមិនក្រខ្សត់ខ្វះមុខខ្វះក្រោយទៀតទេ ។ ប៉ុន្តែលទ្ធផលដែលខ្ញុំបានទទួល គឺ ម៉ែគ្រវីក្បាល ហើយពោលមកកាន់ខ្ញុំ ៖

- ប្អូនអាន់ ! ម៉ែយល់ពីគោលបំណងល្អរបស់កូនហើយ ។ កូនចង់រកចិត្តខ្មែររស់នៅថ្មី ដើម្បីលើកស្ទួយជីវភាពគ្រួសារ ដើម្បីគេចពីសង្គ្រាម ព្រោះខេត្តសៀមរាបយើងនេះ ជាមូលដ្ឋានរបស់បដិវត្តន៍ឡាវមួយ

ដែរ ។ ប៉ុន្តែកូនអើយ ! កូនគិតមើលចុះ ឪពុករបស់កូនមានវ័យចាស់ គាត់នៅតែស្ម័គ្រចិត្តទៅធ្វើការតស៊ូក្នុងព្រៃទៀត ។ បងប្អូនរបស់ឯងទាំងបីនាក់ទៀត ក៏ចូលធ្វើឥស្សរៈឡាវគ្មានសល់ ។ ហ៊ឺ . . . កូនប្រុសខាងម្ដាយ បើកូនជាកុលបុត្ររបស់ជាតិឡាវមែន កូនត្រូវតែទៅធ្វើការតស៊ូជាមួយនឹងឪពុករបស់ឯង ដើម្បីរំដោះទឹកដី មាតុភូមិជាទីស្នេហា ចេញពីទឹមត្រួតត្រារបស់អាណានិគមនិយមបារាំងណាកូន . . . ព្រោះបញ្ហាប្រទេសជាតិ ធំជាងរឿងគ្រួសារឆ្ងាយណាស់ លើសពីនេះ ម៉ែមិនចង់ទៅស្លាប់នៅទីណា ក្រៅពីនៅលើទឹកដីកំណើតរបស់យើងទេកូនធំ ។

បានស្ដាប់ពាក្យសំដីដែលពោរពេញដោយខ្លឹមសារ ប្រៀនប្រដៅរបស់អ្នកម្ដាយ ធ្វើឲ្យខ្ញុំមានការភ្ញាក់រលឹក ប្រៀបដូចមនុស្សកំពុងតែសន្លប់ហើយត្រូវគេជះទឹកត្រជាក់ដាក់មុខ ។ សតិសម្បជញ្ញៈចាប់ផ្ដើមស្ដីបន្ទោសខ្ញុំ ព្រោះខ្ញុំធ្លាប់ចូលរួមក្នុងចលនាម៉ែកឥស្សរៈឡាវ រហូតត្រូវពួកបារាំងចាប់យកទៅដាក់គុក នៅលើកោះត្រឡាចយ៉ាងកំសត់វេទនា ផុតទោសទើបរួចខ្លួនវិញ ហេតុអ្វីបានជាខ្ញុំបណ្ដោយឲ្យមនសិការស្នេហាជាតិធ្លាក់ចុះខ្សោយយ៉ាងនេះ ។

ប៉ុន្តែទន្ទឹមនឹងគ្នានោះ ខ្ញុំក៏នឹកឃើញដល់សេចក្ដីស្នេហារវាងខ្ញុំនិងមាលា ដែលមានសភាពស្និតរមួត បាត់មុខគ្នាពុំបាន ប្រៀបបាននឹងលលកញីឈ្មោល ។ ខ្ញុំនឹកឃើញនូវពាក្យសន្យារបស់ខ្ញុំជាមួយមាលា និងឪពុកម្ដាយរបស់នាង ដែលអះអាងថា ខ្ញុំនឹងវិលត្រឡប់ទៅភ្នំពេញវិញជាដាច់ខាត ។ ខួរក្បាលរបស់ខ្ញុំចាប់ផ្ដើមដោះស្រាយនូវបញ្ហាស្មុគ



ស្មាញជាទីបំផុត ដែលតាំងពីនឹងក្ដីមក ខ្ញុំពុំដែលជួបប្រទះនឹងបញ្ហាពិបាករបៀបនេះទាល់តែសោះ ។

ម្ខាងគឺសេចក្ដីស្នេហា ជាសេចក្ដីស្នេហាដ៏បរិសុទ្ធដែលខ្ញុំទើបតែនឹងជួបប្រទះជាលើកដំបូងក្នុងជាតជីវិត ។ រីឯម្ខាងទៀតបញ្ហាប្រទេសជាតិមាតុភូមិ ហើយជាដំបូន្មានរបស់អ្នកមានគុណទៅទៀត ។

តើឲ្យខ្ញុំសំរេចចិត្តបែបណា ? . . ខ្ញុំស្រងូតស្រងាត់ ខ្ញុំសញ្ជឹងគិតពិចារណា . . . ខ្ញុំធ្វើការវិភាគវែកញែកតែម្នាក់ឯង អស់ជិតមួយសប្ដាហ៍ ។ ទីបំផុត ខ្ញុំក៏សំរេចចិត្តថា ត្រូវគិតបញ្ហាប្រទេសជាតិជាមុនសិន ។ កាលណាចលនាតស៊ូបានទទួលជ័យជំនះ វាយកំចាត់ពួកអាណានិគមនិយមបារាំងចេញពីទឹកដីឡាវអស់ហើយ បើខ្ញុំមានរាសនានៅគង់វង្សជីវិត ខ្ញុំនឹងទៅរកមាលាភ្លាម នោះក៏ប្រហែលជាពុំទាន់ហួសពេលដែរ ។

តាំងពីថ្ងៃនោះមក ខ្ញុំបានលបលួចធ្វើដំណើរចូលទៅក្នុងប្រទេសវៀតណាម ហើយធ្វើការទាក់ទងជាមួយនឹងចលនាតស៊ូរំដោះជាតិវៀតណាមជាញឹកញាប់ ។ ជាមួយគ្នានោះ ខ្ញុំក៏បានដើរបំផុសចលនាបញ្ចុះបញ្ចូលយុវជនដែលមានវ័យស្របាល ។ គ្នាទៅក្នុងខេត្តសេម៉ូនដោយស្ងាត់កំបាំង ។ ទីបំផុតខ្ញុំក៏ប្រមូលគ្នីគ្នាបានចំនួន២១នាក់ ទើបនាំគ្នាទៅសុំជំនួយពីចលនាតស៊ូរំដោះជាតិវៀតណាមបានកាំភ្លើងចំនួនប្រាំដើម គ្រាប់បីរយគ្រាប់ និងគ្រាប់បែកដៃប្រាំបីគ្រាប់ ។

ថ្ងៃមួយ ខ្ញុំបាននាំគ្នីគ្នាទៅលួចស្ទាក់លបបាញ់រថយន្តដឹកជញ្ជូន

របស់ពួកទាហានបារាំងនៅក្បែរស្ពានមួយ ដណ្ដើមយកបានកាំភ្លើងពីរដើម និងសំភារៈសឹកខ្លះទៀត ។ ប៉ុន្តែក្រោយមក ត្រូវពួកវាលើកគ្នាតាមរុករកវិញ ។ ដោយឃើញសត្រូវមានគ្នាច្រើនលើសលប់ និងអាវុធធ្ងន់ផង ខ្ញុំក៏ពិគ្រោះគ្នាជាមួយនឹងយុទ្ធមិត្តទាំងអស់ ហើយសំរេចចិត្តភៀសខ្លួនឆ្លងដែនចូលទៅប្រទេសវៀតណាម ។

ក្រោយពីស្របយោបល់គ្នាហើយ យើងនាំគ្នាចេញដំណើរជាបន្ទាន់ ដើម្បីរំដោះខ្លួនមួយគ្រាសិន ប៉ុន្តែនៅពេលឆ្លងទន្លេមេគង្គ ស្រាប់តែជួបនឹងការលួចស្ទាក់របស់ពួកទាហានបារាំង បណ្ដាលឲ្យការប្រយុទ្ធផ្ទុះឡើងកក្រើកព្រៃ ។ ដោយពួកបារាំងទើបនឹងបាក់ស្បាតនឹងស្នាដៃរបស់ក្រុមយើងថ្មីៗនិងដោយចិត្តប្ដេជ្ញាយ៉ាងមោះមុតឥតតក់ស្លុតរបស់យុទ្ធមិត្តយើងទាំងអស់ផង យើងក៏បាញ់សំរុកបើកផ្លូវចេញផុតពីការឡោមព័ទ្ធបាន ប៉ុន្តែមានមិត្តបីនាក់ត្រូវរបួសជាទម្ងន់ ។ យើងបានកាប់មែកឈើធ្វើស្នែងសែងអ្នករបួស ធ្វើដំណើរតទៅទៀត ។ គួរឲ្យស្ដាយ ប៉ុន្មានម៉ោងក្រោយមក ស្រាប់តែមិត្តអ្នករបួសម្នាក់ត្រូវផុតជីវិត ។

ក្រោយពីកប់សាកសពមិត្តរួចហើយ យើងក៏បន្តដំណើរតទៅទៀតដោយនាំអ្នករបួសទៅជាមួយយ៉ាងគ្រដាបគ្រដួស ។

អស់រយៈពេលពេញមួយថ្ងៃ ទើបក្រុមរបស់ខ្ញុំទៅដល់ជំរំកងទ័ពឥស្សរៈឡាវ ដែលតាំងនៅក្នុងព្រៃស្រោងលើទឹកដីវៀតណាម ។

☆ ព្រះអង្គម្ចាស់សុផានុវង្ស ដែលជាអ្នកដឹកនាំម្នាក់ក្នុងចលនាតស៊ូបានទទួលដំណឹង ក៏ចេញមកទទួលរាក់ទាក់ និង ពោលសរសើរពី



សេចក្ដីក្លាហានរបស់ក្រុមយើង ។

ចៃដន្យល្អពេលនោះ ខ្ញុំបានឃើញឪពុកខ្ញុំដើរពីក្រោយអ្នកដឹកនាំចលនាសំដៅមកដែរ ។ ខ្ញុំរត់ទៅឱបឪពុកខ្ញុំសំដែងការនឹករលឹកទាំងក្ដុកក្ដួលក្នុងចិត្តឥតឧបមា លាយឡំដោយក្ដីរំភើបត្រេកអរពេកអ្វីប្រៀបផ្ទឹមពុំបាន ។ ផ្ទុយទៅវិញ ឪពុកខ្ញុំមានទឹកមុខស្ងប់ស្ងៀម ហាក់ដូចឥតភ្ញាក់ផ្អើលអ្វីសោះ គាត់ចាប់ស្មាខ្ញុំទាំងសងខាងសម្លឹងមុខខ្ញុំដោយពន្លឺភ្នែកមុត ប៉ុន្តែមានភាពត្រជាក់ និងរីករាយ ហើយពោលដោយសំឡេងពេញចិត្ត ៖

- ម្ចាស់ ! . ឯងធ្វើនេះ ទើបសមជាកូនប្រុសរបស់ពុក ! . .

ឪពុករបស់ខ្ញុំមាំមួនដដែល គ្រាន់ចាស់ជាងមុនបន្តិច ។ ខ្ញុំសួរបង្អើះអ្នកមានគុណ ៖

- បងស្នាក់និគន ប្អូនខាំវែង និង ប្អូនខាំផ នៅឯណាពុក ? . .

- ពួកវានៅក្នុងអង្គភាពផ្សេងៗទៀត ឆ្ងាយៗ ពីទីនេះ ថ្ងៃណាមួយកូនគង់តែនឹងបានជួបបងប្អូនវិញទេ ! . .

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំក៏រស់នៅក្នុងជំរំរបស់ចលនាឥស្សរៈឡាវធ្វើការរស់ជាមួយ នឹង ឪពុករបស់ខ្ញុំ ។ ពេលទំនេរ ខ្ញុំបានរៀបរាប់ប្រវត្តិដ៏ជូរចត់ កាលពីពេលដែលបារាំងចាប់យកទៅដាក់គុកនៅកោះត្រឡាចជាហូរហែដល់រូបគាត់ ។ ហើយក៏មិនភ្លេចនិយាយពីគុណបំណាច់របស់គ្រួសារត្រៀសនៅភ្នំពេញ ដែលបានជួយទំនុកបំរុងដល់រូបខ្ញុំដែរ ។

កម្លាំងតស៊ូរបស់ប្រជាជននៅឥណ្ឌូចិន គាត់តែងតាបនេះសន្ទា

សន្ធាគ្រប់ទីកន្លែងទាំងបីប្រទេស ។ នៅប្រទេសឡាវ រដ្ឋាភិបាលប្រតិកិរិយាដោយដឹងខ្លួនថា ពុំអាចទប់ទល់ចំពោះការតស៊ូយ៉ាងស្វិតស្វាញរបស់ចលនារំដោះជាតិបាន នាឆ្នាំមួយពាន់ប្រាំបួនរយហាសិបប្រាំពីរ ព្រះអង្គម្ចាស់សុវណ្ណភូមា ដែលជាអ្នកដឹកនាំរដ្ឋាភិបាល ក៏បានធ្វើដំណើរមកកាន់ដីរំដោះ ដើម្បីចុះហត្ថលេខា រួមជាមួយនឹងអ្នកដឹកនាំបដិវត្តន៍ឡាវ ស្ដីពីការបង្កើតរដ្ឋាភិបាលបង្រួបបង្រួមជាតិឡាវ ។

បន្ទាប់ពីមានការចុះហត្ថលេខារួចហើយ ឪពុកខ្ញុំក៏វិលត្រឡប់ទៅមាតុប្រទេសវិញជាមួយព្រះអង្គម្ចាស់សុផានុវង្ស ដើម្បីបង្កើតរដ្ឋាភិបាលថ្មី ។ ចំណែកខ្ញុំវិញបានត្រូវចាត់តាំងឲ្យទៅបំពេញការងារក្នុងការផ្សាយលើរលកធាតុអាកាសជាភាសាឡាវនៅវិទ្យុផ្សាយសំឡេងនៃទីក្រុងហាណូយ ព្រោះនៅទីនោះ មានការខ្វះខាតអ្នកចេះនិពន្ធភាសាឡាវ ហើយគេជ្រើសរើសខ្ញុំបញ្ជូនទៅ ដោយថ្នាក់លើដឹងថា ខ្ញុំជាមនុស្សមាននិស្ស័យខាងអក្សរសាស្ត្រ ។

គឺនៅពេលនោះហើយ ដែលខ្ញុំត្រូវបែកពីឪពុកខ្ញុំម្ដងទៀត ហើយព្រំដែនវៀតណាមឡាវក៏ត្រូវបិទហាមលែងឲ្យចេញចូលតទៅទៀតដែរ ។

* *

*



# ១០

## សេចក្ដីព្យាយាម

អ្នកផងតែងនិយាយលេងសើចថា ផែនដីវិល ផ្ទះមនុស្សយើងដែលបែកគ្នា ក៏មិនបែករហូតទេ គង់តែមានថ្ងៃណាមួយជួបគ្នាវិញមិនខាន ។

នៅក្នុងលោកនេះ សំបូររឿងចៃដន្យណាស់ ដូចជាពេលមកធ្វើការនៅវិទ្យុផ្សាយសំឡេងប្រជាជនវៀតណាម នាទីក្រុង ហាណូយ ស្រាប់តែខ្ញុំបានជួបនឹងមិត្តចាស់ម្ដងទៀត ។ ខ្ញុំពិបាកនឹងរកពាក្យពេចន៍មកបកស្រាយឲ្យសមនឹងសេចក្ដីសប្បាយរីករាយនៅពេលដែលយើងទាំងពីរបានជួបគ្នាសាលើកទីបីនេះណាស់ ។ យើងស្រវាឱបគ្នាស្ទើរមិនរបេះ ប្រៀបដូចគូសង្សារដែលព្រាត់យូរឆ្នាំ ។

មិត្តចិន្ទបានត្រូវបក្សប្រជាជនបដិវត្តន៍ខ្មែរ ចាត់តាំងឲ្យមកធ្វើការបំរើការងារផ្សាយជាភាសាខ្មែរ តាមរលកធាតុអាកាសវិទ្យុជាមួយនឹងមិត្តនារីកម្ពុជាពីរនាក់ទៀត តាំងពីខ្ញុំមិនទាន់មកដល់ម្ល៉េះ ។

ខ្ញុំធ្វើការនៅវិទ្យុផ្សាយសំឡេងប្រជាជនវៀតណាម ដោយសុខសប្បាយពុំដែលមានពលមោសអ្វីសោះ ។ ចាប់ផ្ដើមធ្វើការដំបូង ប្រធាន

ការិយាល័យនិពន្ធ បានចាត់បង្គាប់ឲ្យខ្ញុំសរសេរអំពីប្រពៃណី និង ទំនៀមទម្លាប់របស់ប្រជាជនឡាវ ដើម្បីផ្សាយតាមរលកធាតុអាកាសក្នុងឱកាសបុណ្យជាតិឡាវ ។

ខ្ញុំមានសេចក្តីត្រេកអរលាយឡំជាមួយនឹងការព្រួយបារម្ភ ហើយខិតខំធ្វើការនេះដោយផ្ចិតផ្ចង់ជាទីបំផុត ។ លុះសរសេរស្រេចបាត់ហើយ ខ្ញុំក៏យកអត្ថបទទៅជូន សមមិត្ត ប្រធានការិយាល័យនិពន្ធដែលជាជនជាតិវៀតណាម ។ សមមិត្ត ប្រធានត្រួតពិនិត្យមួយចប់ហើយ ក៏គូសលុបនិងពន្យល់ប្រាប់អំពីចំណុចខ្វះខាតជាច្រើន ទើបប្រគល់មកឲ្យខ្ញុំយកទៅចងក្រងសាជាថ្មីឡើងវិញ ។

ដោយសារមានការណែនាំ ការនិពន្ធជាលើកទីពីរនេះ ខ្ញុំយល់ឃើញខ្លួនឯងថា អត្ថរសនិងអត្ថន័យបានល្អប្រសើរជាងលើកមុន ។ ប៉ុន្តែ បន្ទាប់ពីត្រួតពិនិត្យរួចហើយ សមមិត្ត ប្រធានការិយាល័យបានកែសម្រួលជាច្រើនអន្លើ ទើបសម្រេចឲ្យគេយកទៅផ្សាយ ។

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំក៏ព្យាយាមកសាងខ្លួនឲ្យទៅជាអ្នកនិពន្ធថ្មីមួយរូប ដោយខិតខំស្រាវជ្រាវឯកសារ និងអានអត្ថបទល្អៗរបស់អ្នកនិពន្ធល្បីល្បាញនានា ។ ដោយសារចំណង់នោះ ខ្ញុំស្រេកឃ្លានការអានសៀវភៅដូចឃ្លានអាហារ ។ ខ្ញុំឧស្សាហ៍ចូលក្នុងបណ្ណាល័យណាស់ សៀវភៅណាដែលខ្ញុំបានឃើញហើយ ពុំបានអាន ខ្ញុំហាក់ដូចតប់ប្រមល់ ស្ទើរដេកពុំលក់ ។

ជារៀងរាល់ថ្ងៃ ខ្ញុំតែងអត្ថបទបានជាច្រើន ប៉ុន្តែអត្ថបទទាំងនោះ



ជួនកាលក៏បានផ្សាយខ្លះ ជួនកាលក៏ពុំបានផ្សាយសោះ ដោយសារខ្លឹមសារឬអត្ថរសពុំបានសម្រេចតាមសេចក្តីត្រូវការរបស់ការិយាល័យនិពន្ធ ។

ទោះបីជាយ៉ាងណាក៏ដោយ ដោយសារកិច្ចការបង្ខំនិងចិត្តអំណត់ផង ខ្ញុំក៏នៅតែព្យាយាមស្រាវជ្រាវនិងនិពន្ធទាំងយប់ទាំងថ្ងៃ ដោយគ្មានការអាក់អន់ស្រពន់ចិត្តឬអស់សង្ឃឹមឡើយ ។ មិនយូរប៉ុន្មាន កិច្ចការរបស់ខ្ញុំក៏បានចំរើនជឿនលឿនជាក់ស្តែង។ អត្ថបទភាគច្រើនរបស់ខ្ញុំសុទ្ធតែត្រូវបានយកទៅផ្សព្វផ្សាយតាមរលកធាតុអាកាស ហើយសមមិត្ត ប្រធានការិយាល័យនិពន្ធមិនសូវនឿយលំបាកនឹងកែសម្រួលដូចពីដើមទៀតទេ ។

អស់រយៈពេលប្រហែលមួយឆ្នាំកន្លងមកទៀត ខ្ញុំត្រូវបានសមាគមអ្នកនិពន្ធវៀតណាមនៅក្រុងហាណូយ អនុញ្ញាតឲ្យចូលជាសមាជិករបស់សមាគម ។ បន្ទាប់មកទៀត ខ្ញុំក៏ដាក់ពាក្យសុំចូលរៀនក្នុងសាលានិពន្ធអស់រយៈពេលពីរឆ្នាំ ។

ថ្វីបើខ្ញុំជាប់សិក្សាមែន ប៉ុន្តែខ្ញុំនៅតែនិពន្ធអត្ថបទផ្សាយតាមវិទ្យុជាញឹកញាប់ ព្រមទាំងតាមដានស្ថានការណ៍នយោបាយក្នុងប្រទេសឡាវជាប់ជានិច្ច ហើយបានដឹងថា រដ្ឋាភិបាលបង្រួបបង្រួមជាតិឡាវ ត្រូវរលាយរូបរាងទៅវិញ ដោយសារឧបាយកលខ្មៅក្រខ្វក់របស់ចក្រពត្តិអាមេរិក ។ លើសពីនេះ ពួកស្តាំនិយមដែលមានអាមេរិកជាមេក្លោង បានចាប់អ្នកដឹកនាំចលនាបដិវត្ត ដាក់ក្នុងមន្ទីរឃុំឃាំងនៅវៀងចន្ទន៍ បណ្តាលឲ្យប្រជាជនធ្វើបាតុកម្មតវ៉ា ស្ទើរគ្រប់ទីកន្លែងក្នុងផ្ទៃប្រទេស ។

កាលនោះ ដោយឃើញខ្ញុំមានអាយុកាន់តែច្រើន ថ្នាក់លើបាន

បង្គាប់ឲ្យខ្ញុំជ្រើសរើសនារីម្នាក់ដែលខ្ញុំពេញចិត្ត ដើម្បីរៀបការយកមកធ្វើជាភរិយា ។ ប៉ុន្តែខ្ញុំបានប្រកែកដោយលេសថា ពុំទាន់ចង់បានគូស្រករទេ ។ តាមការពិត ថ្វីបើឃ្លាតឆ្ងាយពីគ្នាយូរមកហើយក៏ដោយ ចិត្តខ្ញុំនៅតែនឹករលឹកអាឡោះអាល័យដល់នាងមាលា ដែលនៅឯទីក្រុងភ្នំពេញឥតសាយសោះ ។

ជារឿយៗ ខ្ញុំតែងបានជួបប្រាស្រ័យទាក់ទងជាមួយមិត្តចិន និងមិត្តនារីកម្ពុជាពីរនាក់ទៀត ដែលធ្វើការនៅវិទ្យុផ្សាយសំឡេងជាមួយគ្នា ។ កាលណាឃើញនារីកម្ពុជា ចិត្តខ្ញុំចេះតែមមៃនឹកដល់មាលាជានិច្ច ។

បន្ទាប់ពីខ្ញុំចេញពីសាលាណាតិកខ្លួនមិនបានប៉ុន្មានផង នៅថ្ងៃម្ភៃ ខែវិច្ឆិកា ឆ្នាំ មួយពាន់ប្រាំបួនរយហុកសិប ក៏មានពិធីចុះហត្ថលេខារវាងអ្នកដឹកនាំស្តាំនិយម និងអ្នកដឹកនាំបដិវត្តន៍លើកិច្ចព្រមព្រៀងមួយស្តីពីការបង្កើតរដ្ឋាភិបាលចង្រួបចង្រួមជាតិឡាវលើកទីពីរ ។ ពេលនោះ ខ្ញុំក៏វិលត្រឡប់ទៅមាតុភូមិវិញ ហើយចូលធ្វើការនៅវិទ្យុផ្សាយសំឡេងរបស់បក្សអព្យាក្រឹត ។

លុះក្រោយមកទៀត ឧត្តមសេនីយ៍ឯកកុងឡេ បានក្បត់នឹងបដិវត្តន៍ ហើយចុះចូលជាមួយព្រះអង្គម្ចាស់សុវណ្ណភូមា ធ្វើការរំលំរដ្ឋាភិបាលចង្រួបចង្រួមជាតិម្តងទៀត ។ ឃើញដូច្នោះ ខ្ញុំក៏ធ្វើដំណើរទៅខេត្តសាំនឿ ដែលជាខេត្តមូលដ្ឋានយ៉ាងរឹងមាំរបស់ចលនាបដិវត្តន៍ ដើម្បីធ្វើការតស៊ូតទៅទៀត ។

រហូតមកដល់ថ្ងៃទី ដប់បួន កញ្ញា ឆ្នាំ មួយពាន់ប្រាំបួនរយចិតសិបបី



ទើបមានការចុះហត្ថលេខារវាងអ្នកដឹកនាំរបស់រដ្ឋាភិបាលអាយ៉ង និងអ្នកដឹកនាំចលនាបដិវត្តន៍ម្តងទៀត ដើម្បីបង្កើតរដ្ឋាភិបាលចង្រួបចង្រួមជាតិលើកទីបី ។

គិតទៅពេលវេលានៃការព្រាត់ប្រាសរវាងខ្ញុំនិងមាលា ចេះតែបន្លាយការតែវែងឡើងៗ ។ ខ្ញុំនឹករលឹកនាងស្ទើរក្អួតឈាម ណាមួយព្រួយបារម្ភផង ព្រោះបាត់ខ្ញុំយូរពេក ប្រហែលជានាងមានប្តីមានកូនចៅទៅហើយក៏មិនដឹង ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ខ្ញុំនៅតែមានបំណងទៅជួបមុខនាងជាដាច់ខាត ដើម្បីឲ្យអស់ចិត្ត ។

គ្រាន់តែរដ្ឋាភិបាលថ្មីកើតជារូបរាងភ្លាម ខ្ញុំក៏សុំអនុញ្ញាតធ្វើដំណើរទៅប្រទេសកម្ពុជាដែរ ដើម្បីសម្រេចគោលបំណង ប៉ុន្តែរឿងអកុសលមានពុំចេះអស់សោះ ដោយរដ្ឋាភិបាលនេះមានការកៀបសង្កត់ពីពួកស្តាំនិយមខ្លាំងជាងគេ ក៏ពុំព្រមចេញលិខិតឆ្លងដែនឲ្យខ្ញុំសោះ ព្រោះគេដឹងថាខ្ញុំមាននិន្នាការនយោបាយក្រហម ហើយប្រទេសកម្ពុជាកំពុងតែរងគ្រោះសង្គ្រាមយ៉ាងសាហាវដែលសាបព្រោះដោយចក្រពត្តិអាមេរិកដែរ ។

ក្រោយមកនៅខែមេសា ឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំ ខ្ញុំបានទទួលដំណឹងថា ប្រទេសកម្ពុជាបានត្រូវកងកម្លាំងបដិវត្តរបស់ប្រជាជនរំដោះបានទាំងស្រុងហើយ ធ្វើឲ្យខ្ញុំមានសេចក្តីរីករាយជាខ្លាំង ។

បន្ទាប់ពីនោះ មិនបានប៉ុន្មានខែផង នៅប្រទេសឡាវក៏ផ្ទុះព្រឹត្តិ-ការណ៍ថ្មីមួយទៀតដែរ គឺដោយសារទប់ទល់នឹងកម្លាំងបដិវត្តរបស់ប្រជា-ជនទូទាំងប្រទេសពុំបាន ព្រះចៅសាវាងវឌ្ឍនាក៏បានឡាយព្រះហត្ថ-

លេខាលើសេចក្ដីប្រកាសមួយ ដោយសុខចិត្តប្រគល់រដ្ឋអំណាចក្នុងប្រទេសទាំងមូលដល់រដ្ឋាភិបាលបដិវត្តឡាវ នាថ្ងៃទីពីរ ខែ ធ្នូ ឆ្នាំ មួយពាន់ប្រាំបួនរយចិតសិបប្រាំ ។

កងទ័ពរបស់ចក្រពត្តិអាមេរិក បានដកចេញអស់រលីងពីទឹកដីឡាវ ឯកម្លាំងរបស់រដ្ឋាភិបាលអាយ៉ងក៏ដាក់អាវុធចុះចាញ់គ្មានសល់ ហើយសាធារណរដ្ឋប្រជាធិបតេយ្យឡាវដែលប្រកបដោយឯករាជ្យពេញលេញក៏ត្រូវបានប្រកាសបង្កើតឡើង ។

នៅមុននេះប៉ុន្មានខែ កងទ័ពរំដោះជាតិប្រជាជនវៀតណាម ក៏វាយរំដោះយកបាន ភូមិភាគខាងត្បូងប្រទេសដោយជោគជ័យដែរ ។ ដូច្នេះការតស៊ូរបស់ប្រជាជនប្រទេសទាំងបី នៅឥណ្ឌូចិន ក៏បានសម្រេចជាស្ថាពរ ។

លើកនេះ ខ្ញុំមានសេចក្ដីរំភើបត្រេកអរ និង សង្ឃឹមយ៉ាងមុតមាំដោយគិតថា នឹងបានធ្វើដំណើរ មកភ្នំពេញ ជួបមាលាសង្សារបណ្ដូលចិត្តនោះ ទោះបីយើងមានចំណាស់ទៅហើយក៏ដោយ ។ ប៉ុន្តែ ពុទ្ធោអើយ ! .. សេចក្ដីសង្ឃឹមបែរជាត្រូវរលាយដូចអំបិលត្រូវទឹក ព្រោះរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បិទទ្វារព្រំដែនរបស់ខ្លួនពុំអនុញ្ញាតឲ្យជនបរទេសចេញចូល ។ ការទាក់ទងតែជាមួយរដ្ឋាភិបាលចិនប្រជាមានិតតែមួយគត់ ក្រៅពីនោះ ផ្ដាច់ការទាក់ទងជាមួយ ប្រទេសនានាទាំងអស់ លើសកលលោក សូម្បីតែប្រទេសវៀតណាម ដែលជាអ្នកភូមិផងរបងជាមួយ ធ្លាប់រួមលេណដ្ឋានតាំងពីវាយអាណានិគមនិយមបារាំង ពួកហ្វាស៊ីស្តជប៉ុន



រហូតមកដល់ចក្រពត្តិអាមេរិកក៏ដោយ

មតិជឿនលឿនលើឆាកអន្តរជាតិ មានការងឿងឆ្ងល់ និងសោកស្ដាយជាខ្លាំង ចំពោះគោលនយោបាយជ្រុលលេលា របស់បក្សកុម្មុយនីស្តកម្ពុជារបស់ប៉ុលពត ។

ចំណែកខ្លួនខ្ញុំផ្ទាល់វិញ ខ្ញុំចាត់ទុកថារដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជាព្រាយបិសាចដ៏ចង្រៃដែលបានផ្ដាច់កំទេចមនោសញ្ចេតនាស្នេហាបរិសុទ្ធស្មោះត្រង់ របស់ខ្ញុំចំពោះមាលា ឲ្យម៉ដ្ឋដូចផង់ធូលី ហើយបាចចោលទៅក្នុងគក់ផ្សៅ ។

បន្ទាប់ពីប្រទេសឡាវបានឯករាជ្យហើយ ខ្ញុំបានបញ្ចេញអស់កម្លាំងចិត្តនិងកម្លាំងកាយបំរើបក្សនិងរដ្ឋ តាមរយៈស្នាដៃនិពន្ធរបស់ខ្លួន ។ តាំងពីពេលដែលនៅតស៊ូក្នុងព្រៃរហូតមកទល់សព្វថ្ងៃ ខ្ញុំតាក់តែងស្នាដៃបានជាច្រើនរាប់មិនអស់ ខ្លះជាអត្ថបទកំណាព្យ ខ្លះជារឿងប្រលោមលោក ។ ពីមួយថ្ងៃទៅមួយថ្ងៃ ឈ្មោះរបស់ខ្ញុំកាន់តែល្បីរន្ទឺសុសសាយគ្រប់មជ្ឈដ្ឋានដោយបានទទួលការសរសើរ ស្រឡាញ់រាប់អានពីអ្នកអានគ្រប់ប្រភេទ ។ លើសពីនេះ ខ្ញុំត្រូវមិត្តអ្នកនិពន្ធឯទៀតៗ ចាត់ទុកថា ជាអ្នកនិពន្ធរៀបចង មិនមែនជាអ្នកនិពន្ធវ័យក្មេងដូចមុនទៀតទេ ។

ប៉ុន្តែជាមួយកេរ្តិ៍ឈ្មោះនិងកិត្តិយសដ៏ត្រអូបនេះ ពេលវេលាក៏ចេះតែទៅមុខដូចទឹកហូរពុំវិលត្រឡប់ អូសទាញនាំយកទាំងយុវវ័យរបស់ខ្ញុំទៅបាត់គួរស្ដាយស្រណោះ ។ ឯណាទៅសុភមង្គលក្នុងជីវិត បើខ្ញុំត្រូវព្រាត់និរាសពីនារីជាទីស្រឡាញ់អស់រយៈកាលម្ភៃឆ្នាំមកហើយ ។ ប៉ុន្តែ ខ្ញុំ

នៅតែចិញ្ចឹមចិត្ត ចង់ឃើញមុខនាងជាចុងក្រោយម្ដងទៀត ឲ្យអស់ចិត្ត ទោះបីនាងក្លាយទៅជាអ្នកស្រីម្នាក់ ដែលមានបុត្រាបុត្រីហើយក៏ដោយ ។

* *



# ១១

## មេឃបាក់ផ្លូវច័ន្ទ

ពីមួយឆ្នាំទៅមួយឆ្នាំ ខ្ញុំកាន់តែមានការព្រួយបារម្ភឡើងចំពោះវាសនារបស់មាលានិងគ្រួសាររបស់នាង ព្រោះប្រទេសកម្ពុជាទើបនឹងឆ្លងកាត់ផុតពីសង្គ្រាមដ៏កាចសាហាវអស់រយៈពេលប្រាំឆ្នាំ ស្រាប់តែឥឡូវ ពត៌មានល្អិតល្អៀងថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានធ្វើទុក្ខបុកម្នេញ និងកាប់សម្លាប់ប្រជាជនរបស់ខ្លួនយ៉ាងឃោរឃៅព្រៃផ្សៃទៀត ។

ហេតុដល់ឆ្នាំ មួយពាន់ប្រាំបួនរយចិតសិបប្រាំបី ដំណឹងកាន់តែច្បាស់លែងសង្ស័យ ព្រោះកងទ័ពកម្ពុជាប្រជាធិបតេយ្យរបស់ប៉ុលពត បានវាយលុកឈ្លានពានទន្ទ្រានទី ចូលដល់ខេត្តខ្លះរបស់វៀតណាមដែលនៅជាប់នឹងព្រំដែន ប៉ុន្តែក៏មានកម្មាភិបាល កងទ័ពនិងប្រជាជនកម្ពុជាជាច្រើនបានរត់គេចខ្លួនចូលទៅជ្រកកោននៅក្នុងប្រទេសវៀតណាម ។

លុះដល់ខែមករា ឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួន អ្វីៗដែលត្រូវកើតឡើង ស្រាប់តែកើតឡើង . . . ។ កងទ័ពបដិវត្តកម្ពុជាដែលមានការឧបត្ថម្ភគាំទ្រពីកងទ័ពប្រជាជនវៀតណាម បានសហការគ្នាវាយរំដោះប្រទេសកម្ពុជាទាំងមូល ពីកណ្ដាប់ដៃប្រឡាក់ឈាមរបស់រដ្ឋា-

ភិបាលប្រល័យពូជសាសន៍របស់ជនប៉ុលពត អៀងសារី ខៀវសំផនបាន ទទួលជោគជ័យជាស្ថាពរ ។

រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏ត្រូវបានប្រកាស បង្កើតឡើង ។ ប្រជាជនដែលសេសសល់ពីការកាប់សម្លាប់របស់ពួក កញ្ជះចិនចេកវ៉េង ក៏ធ្វើដំណើរត្រឡប់ពីទីកន្លែងផ្សេងៗ ដែលគេជម្លៀស ទៅ វិលត្រឡប់មកភូមិកំណើតវិញយ៉ាងពាកកពូន ។ ជីវិតប្រជាជន កម្ពុជាក៏ចាប់រស់ឡើងវិញជាថ្មី ។

ក្រោយពីរដ្ឋអំណាចដ៏ក្មេងខ្ចី របស់រដ្ឋាភិបាលកម្ពុជាថ្មី បានរឹង មាំហើយ ខ្ញុំក៏ត្រូវបានរដ្ឋាភិបាលឡាវចាត់តាំងជាប្រធានគណៈប្រតិភូ អ្នកនិពន្ធឡាវឲ្យមកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា ដើម្បីស្រាវ ជ្រាវពីអំពើឧក្រិដ្ឋដ៏យង់ឃ្នងរបស់ជនឃាតករប៉ុលពតដែលបានប្រព្រឹត្តទៅ លើប្រជាជនកម្ពុជា ក្នុងគោលដៅយកទៅចងក្រងជាបទនិពន្ធផ្សព្វផ្សាយ ដល់ប្រជាជនឡាវឲ្យបានដឹងច្បាស់ ។

គណៈប្រតិភូរបស់យើង ត្រូវបានបណ្ដា សមមិត្ត កម្មាភិបាលនៅ ក្រសួងឃោសនាការនិងវប្បធម៌កម្ពុជា នាំទៅទស្សនាសារមន្ទីរជាតិអតីត វាំង គុកទួលស្លែងនិងមណ្ឌលពិឃាតផ្សេងៗទៀត ដែលបន្សល់ទុកនូវ ស្លាកស្នាមនៃអំពើឧក្រិដ្ឋរបស់ជនប៉ុលពត ។ គំនរឆ្អឹងដូចដំបូក រណ្ដៅ កប់រួមរាប់រយពាន់ ខ្នោះឃ្នាងច្រវាក់ ក្រចៅ និងវត្ថុផ្សេងៗទៀត ដែល ជនឃាតករ ធ្លាប់ប្រើប្រាស់សំរាប់ធ្វើទារុណកម្មអ្នករងគ្រោះ បានធ្វើឲ្យ គណៈប្រតិភូយើងស្រៀវស្រើបនិងខ្លោចផ្សា រហូតមានអ្នកខ្លះស្រក់ទឹក



ភ្នែកផង ។

តាំងពីនៅទីក្រុងដល់ខេត្តក្រៅ កន្លែងណាក៏ឃើញស្លាកស្នាមនៃ សង្គ្រាមនិងសំណល់នៃការបំផ្លិចបំផ្លាញ របស់ជនប៉ុលពតដែរ តាំងពីផ្ទះ សំបែង ផ្លូវគមនាគមន៍ ស្ពាន អគារផ្សេងៗ រហូតដល់សំភារៈគ្រប់បែប យ៉ាង ។

ខ្ញុំបានស្នើទៅកម្មាភិបាលពិធីការកម្ពុជា ដើម្បីសុំទៅស្រាវជ្រាវ ស្រាវជ្រាវរកគ្រួសាររបស់មាលា ។ សមមិត្ត ទាំងនោះ បានអះអាង ជួយសំរួលរឿងនេះដល់ខ្ញុំដោយរីករាយ ។ រសៀលថ្ងៃមួយ គេបាន រៀបចំទូកម៉ាស៊ីនមួយ ជូនខ្ញុំទៅជួបចំណងមែន ។ ពេលជិះទូកឆ្លងទន្លេ សាប ខ្ញុំរំភើបត្រេកអរផង ព្រួយបារម្ភខ្លាចរកមាលាពុំឃើញផង ហើយ នឹកស្រមៃដល់កាលពីជាងម្ភៃឆ្នាំមុន ដែលនាងបានជូនខ្ញុំឆ្លងមកកំពង់ផែ ដើម្បីនឹងឡើងកប៉ាល់ធ្វើដំណើរទៅស្រុកកំណើត ។ ស្រមោលអតីតកាល ដ៏ផ្អែមល្ហែមបានផុសឡើងវិញយ៉ាងរស់រវើក ក្នុងអារម្មណ៍របស់ខ្ញុំប្រៀប បីដូចខ្សែភាពយន្ត ។

តាំងពីថ្ងៃនោះមក យើងបែកគ្នារហូត ។ ខ្ញុំពុំដែលបានទទួល ដំណឹងពីនាងសូម្បីបន្តិចបន្តួចសោះ ឥឡូវនេះក្នុងវ័យចំណាស់ តើនាង មានមុខមាត់បែបណា ? តើនាងនៅចាំខ្ញុំឬទេ ? ខ្ញុំគិតថា បើនាង ជានាងមានប្ដីទៅហើយ ក៏ខ្ញុំពុំតូចចិត្តដែរ ព្រោះពេលវេលាកន្លងមកយូរ ពេក ។ ចុះរឿងដែលគួរឲ្យព្រួយបារម្ភជាខ្លាំងនោះ គឺប្រទេសកម្ពុជា បានឆ្លងកាត់សង្គ្រាមប្រាំឆ្នាំ ឆ្លងកាត់របបប្រល័យពូជសាសន៍ជិតបួនឆ្នាំ

តើមាណាមានតំណាងសាសនាចាស់នៅឬទេ ? . .

ឡើងដល់ក្រោយចង្វា ខ្ញុំស្រាលខ្លួនស្ទើរ ព្រោះទិដ្ឋភាពប្រែប្រួលខុសពីកាលជាងម្ភៃឆ្នាំមុនឆ្ងាយណាស់ ។ ក្រៅពីស្ពានមួយដែលទើបនឹងស្ថាបនាហើយ ត្រូវបំផ្លិចបំផ្លាញដោយសារសង្គ្រាមនោះ ផ្ទះសំបែងនានា ត្រូវរលាយបាត់ស្រមោលអស់ស្ទើរគ្មានសល់ ។ ដីភូមិត្រូវគប់បាត់ដោយដំណាំចាស់និងព្រៃដែលទើបដុះថ្មីលាយឡំគ្នា ។

តាមការរៀបរាប់ប្រាប់របស់សមមិត្តពិធីការកម្ពុជា ឲ្យដឹងថា ភូមិស្ពានទាំងនេះ ទើបនឹងត្រូវវិនាសអន្តរាយ ក្នុងសម័យដែលបន ប៉ុលពត កាន់អំណាចទេ ។

អស់រយៈពេលប្រហែលមួយម៉ោង ទើបខ្ញុំរកឃើញដីភូមិដែលជាទីតាំងរបស់មាណាពីដើម ព្រោះចំណាំដើមអំពិលនិងព្រះវិហារកាតូលិកនៅក្បែរនោះ ។ ថ្វីបើដើមអំពិលលាស់ធំខ្លែកជាងពីមុនច្រើន ប៉ុន្តែការនៅតែរក្សាចំងាយពីព្រះវិហារដដែល ហើយខ្ញុំចាំច្បាស់ថា នៅភូមិនេះមានតែដើមអំពិលតែមួយគត់ ។

ដើមអំពិលនៅកន្លែងដដែល ទឹកទន្លេសាបនៅមានពណ៌ដូចកាលពីជាងម្ភៃឆ្នាំមុន ប៉ុន្តែផ្ទះរបស់គ្រួសារពូរ៉ុស ដែលខ្ញុំធ្លាប់ជ្រកកោនបាត់រូបរាងទៅហើយ ស្រាប់តែលេចខ្ទមតូចមួយផ្ទាល់ដី ដែលទើបនឹងសង់ថ្មីជំនួសវិញ ។ ខ្ញុំឈរសម្លឹងទិដ្ឋភាពនេះ ទាំងភ្ញាក់ភ្នាំង ហើយច្រួលច្របល់ក្នុងចិត្តជាខ្លាំង ។ សមមិត្តអ្នកនិពន្ធឡាវនិងកម្ពុជា ដែលជូនដំណើរតាមសង្កេតគ្រប់កាយវិការរបស់ខ្ញុំ ។



ទីបំផុត ខ្ញុំក៏សំរេចចិត្តចូលទៅសួរម្ចាស់ផ្ទះ ។ ចូលដល់ឃើញស្ត្រីម្នាក់សម្បុរស្រអែម អាយុខ្ទង់ជាងសាមសិបឆ្នាំ បីកូនតូចមួយនៅនឹងដៃ ។ គាត់មានការភ្ញាក់ផ្អើលនិងងឿងឆ្ងល់ជាខ្លាំង នៅពេលដែលឃើញពួកយើងមានមនុស្សចម្លែកច្រើនចូលទៅជំរាបសួរ ។

ដោយខាននិយាយភាសាខ្មែរយូរឆ្នាំពេក ខ្ញុំភ្លេចពាក្យពេចន៍ច្រើនណាស់ ហើយសំនៀងក៏ពុំបានច្បាស់ ដូច្នេះហើយបានជាពេលខ្ញុំសាកសួរស្ត្រីម្ចាស់ផ្ទះស្តាប់ពុំសូវបាន រហូតទាល់តែខ្ញុំពឹងពាក់ សមមិត្ត កម្ពុជា ដែលជាអ្នកបកប្រែភាសា ។

ផ្តើមដំបូងខ្ញុំសួរ ៖

- សូមអភ័យទោស តើនាងឈ្មោះអ្វីដែរ ? . .

ម្ចាស់ផ្ទះសម្លឹងមុខខ្ញុំ ហើយសម្លឹងមុខអ្នកបកប្រែភាសាទើបឆ្លើយ ៖

- ខ្ញុំឈ្មោះ សារឿន , អត់ទោសលោក តើគាត់ជាជនជាតិអីដែរ ? . .

សមមិត្ត អ្នកបកប្រែភាសាចង្អុលពួកខ្ញុំ ៖

- សមមិត្ត ទាំងអស់នេះ ជាគណៈប្រតិភូអ្នកនិពន្ធឡាវ ដែលមកបំពេញទស្សនៈកិច្ចនៅកម្ពុជាយើង ! . .

ឮដូច្នេះ នាងញញឹមស្រស់ស្រាយជាងមុន ៖

- សូមអភ័យទោស ដោយផ្ទះរបស់ខ្ញុំតូចចង្អៀត ហើយគ្មានកៅអីទទួលអស់លោកឲ្យបានសមរម្យ ! . .

ខ្ញុំថ្លែងអំណរគុណ តាមរយៈអ្នកបកប្រែ ៖

- អរគុណហើយ កុំពិបាកខ្វាយខ្វល់អី ខ្ញុំដឹងថាទុក្ខសោកខ្លះៗ របស់នាងកើតឡើងដោយសារការបំផ្លិចបំផ្លាញរបស់ពួកប៉ុលពត ទាំងអស់ ។ តើនាងធ្លាប់មានផ្ទះនៅទីនេះតាំងពីសង្គមមុន ឬមួយក៏ទើបតែមកនៅក្នុងពេលឥឡូវនេះ !..

នាងសារឿនប្រែទឹកមុខឈឺចាប់មួយរំពេច ៖

- ដីភូមិនេះ ជាកម្មសិទ្ធិរបស់គ្រួសារខ្ញុំ តាំងពីសង្គមចាស់មកម្ល៉េះ ប៉ុន្តែផ្ទះរបស់ខ្ញុំត្រូវពួកអាក្អែកខ្មៅអស់នោះ វារុះរើបំផ្លាញអស់គ្មានសល់បន្តិចទេ!.. ផ្ទះនេះហើយបានជាពេលត្រឡប់មកពីបាត់ដំបងវិញ ប្តីខ្ញុំក៏ដើរប្រមែប្រមូលឈើ និងស័ង្កសីចាស់ៗ សង់បានជាកូនខ្ទមនេះគ្រាន់ជ្រកនៅ !..

ខណៈនោះ ស្រាប់តែមានបុរសម្នាក់ជិះកង់កញ្ចាស់ ដឹកកុមារម្នាក់អាយុប្រហែលដប់ឆ្នាំបត់ចូលមកក្នុងរបង ។ ស្ត្រីម្ចាស់ផ្ទះនិយាយប្រាប់ពួកយើង ៖

- នុះ !.. ប្តីខ្ញុំគាត់ត្រឡប់មកវិញហើយ !..

ចូលមកដល់មុខផ្ទះ ឃើញមានមនុស្សចម្លែកច្រើន បុរសជាប្តីសំដែងអាការៈភ្ញាក់ផ្អើលជាខ្លាំង ។ ក្រោយពេលគាត់ផ្អែកកង់ស្រួលបួលហើយ ពួកយើងក៏ចាប់ដៃសំដែងការគួរសមគ្រប់គ្នា ។

ម្ចាស់ផ្ទះសម្លឹងមុខភរិយាឥតដាក់ ហាក់ដូចចង់សួរថា តើមានព្រឹត្តិការណ៍អ្វីកើតឡើងឬ ?.. ប៉ុន្តែមិនចាំបាច់ឲ្យនាងសារឿនឆ្លើយទាន់ សមមិត្តអ្នកបកប្រែភាសាបញ្ជាក់ប្រាប់មុនពីគណៈប្រតិភូរបស់ខ្ញុំ ។



ខ្ញុំសម្លឹងមុខស្វាមីនាងសារឿនយ៉ាងពិនិត្យពិច័យ ។ គេមានវ័យប្រហែលជាងសាមសិបឆ្នាំ ចិញ្ចើមក្រាស់ ភ្នែកធំ ថ្ពាល់ខ្វា ។ ឃើញទំរង់មុខរបស់គេ ខ្ញុំភ្ញាក់ផ្អើលជាខ្លាំង ព្រោះស្រមៃហាក់ដូចធ្លាប់ស្គាល់នៅទីណាម្តង ប៉ុន្តែល្មះសញ្ជឹងគិតបន្តិច ខ្ញុំក៏អរព្រួច ហើយប្រញាប់សួរលមើល ៖

- ប្អូនឈ្មោះហ៊ិន មែនទេ ?...

បុរសម្ចាស់ផ្ទះ បើកភ្នែកសំដែងការងឿងឆ្ងល់ងក់ក្បាលសារភាព ៖

- បាទ !..

គ្រាន់តែឮចម្លើយរបស់ហ៊ិន ខ្ញុំខ្ទួតចិត្តជាខ្លាំង ព្រោះគេជាប្អូនរបស់មាលាមែន !... ថ្វីបើបែកគ្នាជាងប្រាំឆ្នាំមកហើយ ប៉ុន្តែហ៊ិននៅមានទ្រង់ទ្រាយ និងភិនភាគខ្លះអាចឲ្យខ្ញុំចំណាំបាន ។

ឃើញខ្ញុំមានទឹកមុខរីករាយ ហ៊ិនសួរ ៖

- អស់លោកមានការអ្វី ?..

- ខ្ញុំមកនេះ គឺប្រាថ្នាចង់ជួបនឹងប្អូនឯងហ្នឹងហើយ ( ខ្ញុំនិយាយដោយញ័រៗ ព្រោះក្តីរំភើប )

ឮប្រយោគនេះ ហ៊ិន បើកភ្នែកមូលក្រឡង់សម្លឹងមុខខ្ញុំ ហាក់ដូចកំពុងគិតពីរឿងអ្វីមួយ ។ ខ្ញុំដើរចូលជិតចាប់ស្មាទាំងសងខាងរបស់បុរសម្ចាស់ផ្ទះសួរ :

- ឪពុករបស់ប្អូនឈ្មោះរ៉ុសមែនទេ ?..

ហ៊ិន កាន់តែភ្ញាក់ផ្អើលខ្លាំងឡើង ៖

- បាទ ! ហេតុអ្វីបានជាលោកស្គាល់ ?..

ខ្ញុំរឹតតែញាប់ញ័រក្នុងចិត្តសួរទៀត ៖

- គាត់នៅឯណា ?

- ឪពុកម្ដាយរបស់ខ្ញុំ គាត់ស្លាប់អស់ហើយ !..

គ្រាន់តែឮថា ពុកស្លាប់ ទ្រូងខ្ញុំស្រាប់តែតឹងណែន ដង្ហើមខ្ញុំតឹងស្ទើរដកមិនដល់គ្នា បេះដូងខ្ញុំកញ្ជ្រោល ស្ទើរធ្លាយដើមទ្រូង ។ ខ្ញុំអង្រួនស្មាហ៊ិន ហើយសួរទៀតដោយអួលដើមក :

- បងស្រីរបស់ប្អូនឈ្មោះមាលានោះ នៅឯណាសព្វថ្ងៃនេះ ?

- ហេតុអ្វីលោកស្គាល់គ្រួសារខ្ញុំច្បាស់ម្ល៉េះ ? ឬមួយក៏ ... ( ហ៊ិនសួរ ហើយចំសម្លឹងមុខខ្ញុំ ) ខ្ញុំទប់ទល់នឹងក្ដីក្ដុកក្ដួល ហើយឆ្លើយដោយសំឡេងញ័រៗដាច់ៗ :

- ប្អូនមិនស្គាល់បងទេឬ ? បងឈ្មោះ ឬផាន់ ស៊ីវ៉ាន់ធន់ ធ្លាប់រស់នៅជាមួយគ្រួសាររបស់ប្អូនកាលពីជាងម្ភៃឆ្នាំមុននោះណា !..

- អូ៎! បងឬផាន់! អញ្ចឹងមិញខ្ញុំនឹកសង្ស័យ ឥឡូវនេះត្រូវមែន ( ហ៊ិនស្រែកដោយរំភើប ព្រមទាំងលាតដៃឱបខ្ញុំយ៉ាងតឹង ) ។

សមមិត្តអ្នកនិពន្ធ និង សមមិត្តអ្នកបកប្រែភាសាសំដែងសេចក្ដីរីករាយគ្រប់ៗ គ្នា ព្រោះឃើញខ្ញុំបានជួបនឹងមនុស្សដែលខ្ញុំស្វែងរក ។

ខ្ញុំរំភើបត្រេកអរហួសពេកពាក្យនិយាយលែងបាន ។ ហ៊ិនសម្លឹងមុខខ្ញុំទាំងរលីងរលោងទឹកភ្នែក ពោលរៀបរាប់ ៖

- បងមាលា ទន្ទឹងមើលផ្លូវបងអស់ម្ភៃឆ្នាំ ហេតុអ្វីបានជាបងមិនមករកគាត់សោះ ?.



- ឥឡូវនេះ អ្នកមាលានៅឯណា ( ខ្ញុំសួរសង្កើញដូចមនុស្សស្លុតឈាម )

- គាត់ស្លាប់បាត់ទៅហើយ !..

គ្រាន់តែឮសំដីចុងក្រោយរបស់ហ៊ិន ខ្ញុំហ៊ុំងត្រចៀកអ៊ុំង រន្ធត់ក្នុងវិញ្ញាណស្ទើរស្លុតដួល ហើយខ្លួនអារម្មណ៍ហាក់ដូចកំពុងស្ថិតនៅក្នុងពិភពមួយដ៏ស្ងាត់ស្ងៀមសូន្យឈឹង គ្មានខ្យល់ដកដង្ហើមបន្តិចសោះ ។ ខ្ញុំសង្កើញសួរដោយសំឡេងប្លែកពីធម្មតា ៖

- ថាម៉េច !.. អ្នកមាលាស្លាប់ទៅហើយ !..

ហ៊ិន ងក់ក្បាលដោយទឹកមុខស្រងូតស្រងាត់ ។ ខ្ញុំបែរមុខចេញក្រៅ ព្រោះមិនចង់ឲ្យអ្នកឯទៀតឃើញទឹកភ្នែក ដែលកំពុងតែហូរស្រក់កាត់ថ្ពាល់ស្វិតចាស់របស់ខ្ញុំ ។

មួយសន្ទុះ ដើម្បីទាញបរិយាកាសកុំឲ្យធ្លាក់លិចលង់ទៅក្នុងសភាពខ្លោចផ្សាយូរពេក ហ៊ិនក៏ណែនាំភរិយាឲ្យស្គាល់ខ្ញុំ រួចហើយនាងផលិកសួរដេញដោលខ្ញុំពីរឿងដែលខ្ញុំពុំបានវិលត្រឡប់មកវិញតាមសន្យា ទាំងបន្ទាយពេលវេលារហូតជាងម្ភៃឆ្នាំ ទើបលេចមុខយ៉ាងនេះ ។

ខ្ញុំបានសំដែងការសោកស្ដាយ អំពីការពិតក្នុងដំណើរជីវិតរបស់ខ្ញុំដោយត្រួសៗ ហើយគូសបញ្ជាក់ប្រាប់អំពីបញ្ហាបដិវត្តន៍រំដោះជាតិ ដែលបង្ខំឲ្យខ្ញុំរាក់ទាក់ពុំបានវិលត្រឡប់មកភ្នំពេញវិញតាមពាក្យសន្យា ។

បន្ទាប់មក ហ៊ិនដោះអាវចេញ ទាញក្រមាមកជូតញើស ហើយពោលរៀបរាប់យ៉ាងហូរហែ :

- បងប្អូនអើយ កាលណានឹកដល់មាលាបង ខ្ញុំសែនខ្លោចផ្សា ណាស់ ព្រោះចាប់តាំងពីថ្ងៃដែលបងឃ្លាតទៅ បងមាលាកើតទុក្ខរហូត ពុំដែលសប្បាយរីករាយសោះ ។ ជាក់ស្ដែងក៏ឯបងជាងមួយឆ្នាំ គាត់នឹក បងពេករហូតធ្លាក់ខ្លួនឈឺជាទម្ងន់ ។ លុះព្យាបាលជាសះស្បើយហើយ ស្រាប់តែគាត់មានរោគឲ្យពិការយារម្ដែកខុសពីដើម ។ គិតចង់ស្រវានិយាយ ស្ដីជាមួយអ្នកណាសោះ សូម្បីតែមនុស្សក្នុងគ្រួសារក៏ដោយ ។

រាល់ថ្ងៃ បងមាលាចេញចូលសម្លឹងតែរូបថតរបស់បង មានឆ្នាំ មួយនោះ បងមាលាបានសុំពុកឲ្យជូនគាត់ទៅរកបងនៅឯប្រទេសឡាវ ។ ទាំងពុកទាំងម៉ែគាត់អាណិតអាសូរបងមាលាណាស់ ប៉ុន្តែគាត់គ្មានលទ្ធ ភាពនឹងជូនទៅបាន ធ្វើឲ្យបងស្រីរបស់ខ្ញុំដេកស្រក់ទឹកភ្នែករាល់ថ្ងៃ ។ បង ដឹងទេ មានគេចូលស្ដីដណ្ដឹងបងមាលាពីរបីនាក់ដែរ ប៉ុន្តែគាត់ប្រកែកដាច់ អហង្ការពុំព្រមទទួលសោះ ។ លុះយូរៗទៅ ដោយអ្នកស្រុកអ្នកភូមិគេ ដឹងថាគាត់រង់ចាំបង ក៏គ្មានអ្នកណាហ៊ានចូលស្ដីគាត់ទៀតសោះ ។

បងមាលារង់ចាំបងអស់ជាច្រើនឆ្នាំ រហូតក្លាយទៅជាក្រមុំចាស់ មួយរូប ប៉ុន្តែគាត់ហាក់គ្មានការសោកស្ដាយអ្វីសោះ ។ នៅឆ្នាំមួយពាន់ ប្រាំបួនរយចិតសិប ពេលដែលសង្គ្រាមទើបនឹងចាប់ផ្ដើមឆាបឆេះលើទឹក ដីកម្ពុជា ខ្ញុំក៏បានរៀបការប្រពន្ធដែរ ( ហ៊ិនចន្ធូលមុខប្រពន្ធ ) ។ មួយ ឆ្នាំក្រោយមកទៀត មានទាហានជើងទឹកម្នាក់ពាក់សក្តិពីរ ពោះម៉ាយបាន ចូលស្ដីដណ្ដឹងបងមាលាទៀត ប៉ុន្តែគាត់នៅតែប្រកែកដដែល ទោះជា ពុកនិងម៉ែអង្វរយ៉ាងណាក៏ដោយ ។



នៅឆ្នាំមួយពាន់ប្រាំបួនរយចិតសិបបួន ម៉ែខ្ញុំត្រូវស្លាប់ដោយសារ គ្រាប់រ៉ុក្កែតនៅឯភ្នំពេញ ។

លុះដល់ឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំ ក្រោយពួកខ្មែររំដោះ វាយយកបានទីក្រុងភ្នំពេញ គ្រួសារខ្ញុំត្រូវគេជម្លៀសទៅនៅខេត្តបាត់ ដំបង ។ នៅស្រុកនេះ ក្មួយរបស់ខ្ញុំពីរនាក់ត្រូវស្លាប់ដោយសារឈឺគ្មាន ថ្នាំព្យាបាល និងស្រេកឃ្លាន ។ ឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំពីរ ពុកត្រូវគេយកទៅសម្លាប់ ព្រោះតែគាត់ដកដំឡូងដែលដាំខ្លួនឯងនៅ ក្បែរផ្ទះមកស្ងោរហូប ។ មកដល់កម្ពុជាយូរថ្ងៃហើយ បងប្រហែលជា បានជ្រាបខ្លះៗជាមិនខាន អំពីទុក្ខវេទនា និងសេចក្ដីឈឺចាប់គ្រប់បែប យ៉ាងដែលបក្សពួកប៉ុលពត អៀងសារី ខៀវសំផន បានធ្វើទុក្ខបុកម្នេញ ប្រជាជនក្នុងរយៈពេលដែលវាកាន់អំណាច ។ ហ៊ុ ! បងប្អូនអើយ . . . តើបងដឹងថា បងមាលាស្រឡាញ់បងប៉ុណ្ណាទេ ? . .

រៀបរាប់ដល់ត្រង់នេះ ហ៊ិនស្រាប់តែស្រក់ទឹកភ្នែកអួលដើមក និយាយលែងចេញ ធ្វើឲ្យអ្នកស្ដាប់ទាំងប៉ុន្មាន ស្លុតវិញ្ញាណទៅក្នុងអារម្មណ៍ ទុក្ខខ្លោចផ្សាជាមួយដែរ ។

បន្ទាប់មក ហ៊ិនស្ទុះចូលទៅក្នុងរោងនន បើកហិបរើកកាបូប លុះ ចេញមកវិញឃើញកាន់រូបថតមួយសន្លឹកទំហំប៉ុនសៀវភៅសរសេរ មក ហុចឲ្យខ្ញុំ :

- រូបថតនេះ គាត់ថតនៅឆ្នាំមួយពាន់ប្រាំបួនរយចិតសិបបី

ខ្ញុំទទួលរូបថតយកមកមើលយ៉ាងរហ័ស ព្រោះខ្ចង់ចិត្តក្រៃលែង ។

រូបនេះ មាលាកាត់អាវសមខ្លាក់សក់មកក្រោយ ។ អាយុរបស់នាងខ្ទង់ជាងសាមសិបឆ្នាំទៅហើយ ប៉ុន្តែនៅតែស្អាតប្រិមប្រិយគួរឲ្យចាប់ចិត្តចំពោះភ្នែកបុរសខ្លះទៀត ប៉ុន្តែស្នាមញញឹមរបស់នាង មានសភាពស្ងប់ស្ងួតបង្ហាញថាភាពអស់សង្ឃឹមគួរឲ្យអាសូរ ។

ខ្ញុំបើកសំពៀតដកយករូបថត ដែលនាងបានឲ្យខ្ញុំជាអនុស្សាវរីយ៍កាលពីជាងម្ភៃឆ្នាំមុនមកផ្ទឹមមើល ។ រូបថតមុនតូចចាស់ ហើយពណ៌ទៅហើយ ប៉ុន្តែរូបមាលានៅក្មេងល្អ ញញឹមយ៉ាងរីករាយ ផ្ទុយគ្នាស្រឡះពីរូបថតថ្មី ។

ខ្ញុំជាអតីតយុទ្ធជនក្នុងកងទ័ពរំដោះជាតិខ្មែរ ធ្លាប់ប្រយុទ្ធក្នុងសមរភូមិក្តៅគាច្រើនលើកច្រើនសាដែរ ប៉ុន្តែពេលនេះ បេះដូងរបស់ខ្ញុំហាក់ជាទន់ជ្រាយរហូតកុំអាចទប់ទឹកភ្នែកកុំឲ្យហូរចុះបានឡើយ ។ ខ្ញុំខំព្យាយាមសំរួលខ្យល់ដកដង្ហើមសួរ ៖

- ហេតុអីបានជាមាលាស្លាប់ ?..

ហ៊ានសម្លឹងមុខខ្ញុំបន្តិច ទើបឆ្លើយ ៖

- បងមាលាស្លាប់ ព្រោះតែស្រឡាញ់បងធ្ងន់ពេក !

ឮចម្លើយនេះ ទាំងខ្ញុំទាំងអ្នកផងទៀតកើតក្តីងឿងឆ្ងល់ជាខ្លាំង ហើយស្រវាចពត់ភ្នែកទៅលើរូបហ៊ានដែលចាំស្តាប់គ្រប់គ្នា ។ ហ៊ានសម្លឹងទៅឆ្ងាយ ហាក់នឹកលើករឿងអតីតកាលហើយរៀបរាប់បន្ត ៖

- បន្ទាប់ពីពេលគេយកពុកទៅសម្លាប់បានប្រហែលជិតមួយឆ្នាំ ស្រាប់តែអង្គការដាក់ផែន ឲ្យបងមាលារៀបការជាមួយនឹងបុរសពោះ



ម៉ាយម្នាក់ជាប្រធានមន្ទីរស្ថាន ។ ឆ្នាំនោះគាត់អាយុសែសិបប្រាំបួនឆ្នាំទៅហើយ ។ មិនមែនមានតែបងមាលាទេដែលត្រូវរៀបការ នៅមានគូស្រករដប់ម្ភៃគូទៀត ប៉ុន្តែបងមាលាប្រកែកកុំព្រមរៀបការសោះ។ ប្រធានឈ្លបបានហៅគាត់ទៅកសាងណែនាំពីរ បីដង ។ បងដឹងទេការកសាងណែនាំរបស់ពួកអាប៉ុលពតនោះ គឺគ្មានអ្វីក្រៅពីការគំរាមកំហែងដោយពាក្យសំដីទេ ។ លុះដល់ថ្ងៃរៀបការហើយ បងមាលានៅតែកុំព្រមទៀត ព្រោះចិត្តគាត់នឹកលើកទៅបងម្នាក់គត់ប៉ុណ្ណោះ ធ្វើឲ្យពួកអាមហាឃោរឃៅនោះខឹង ហើយចាប់គាត់ចងបណ្តើរយកទៅវាយសម្លាប់នៅក្នុងព្រៃមួយឈ្មោះ ពោធិព្រាប ទាំងរសៀលកុំបាច់ចាំយប់ទាន់ផង ។

ស្តាប់មកដល់នេះ មានមិត្តរបស់ខ្ញុំខ្លះក៏ពុំអាចទប់ទឹកភ្នែកចំពោះព្រឹត្តិការណ៍ដ៏សែនខ្លោចផ្សា របស់គ្រួសារអភ័ព្វនេះបានដែរ ។ ខ្ញុំលូកដៃយកកន្សែងតូចពីហោប៉ៅមកជូត ដើម្បីទប់ទឹកចិត្តខ្លោចផ្សាកុំឲ្យពុះកញ្ជ្រោលខ្លាំងពេក ។

ហ៊ានងាកសម្លឹងមនុស្សជុំវិញខ្លួនមួយសន្ទុះ ទើបពោល ៖

- បន្ទាប់ពីកងទ័ពរណសិរ្សសង្គ្រោះជាតិ និង កងទ័ពវៀតណាមវាយកំទេចបក្សពួកប៉ុលពត រំដោះប្រទេសកម្ពុជាបានហើយ ខ្ញុំក៏ដូចជាប្រជាជនឯទៀតដែរ នាំគ្នាប្រញាប់ប្រញាល់ធ្វើដំណើរត្រឡប់មករកផ្ទះសំបែងវិញ ។ ដូចបងឃើញស្រាប់ហើយ ខ្ទមតូចនេះ ជាជំរកថ្មីរបស់គ្រួសារខ្ញុំ ។ ពួកបងជាគណៈប្រតិភូអ្នកនិពន្ធខ្មែរ កាលណាបានញៀញទៅដល់

មាតុប្រទេសវិញ សូមជួយមិត្តខ្មែរអ្នកបរទេសផ្សព្វផ្សាយឲ្យបងប្អូនប្រជាជនខ្មែរ និងសកលលោក គេបានដឹងពីអំពើ ឧក្រិដ្ឋរបស់របបប្រល័យពូជសាសន៍ របស់ពួកក្បត់ប៉ុលពត ដែលបានប្រព្រឹត្តមកលើប្រជាជនកម្ពុជាផង ។

មិត្តរបស់ខ្ញុំម្នាក់ ដែលបានកត់ត្រាតាំងពីដើមដំបូងរហូតបញ្ចប់ ក៏លូក ដៃចាប់ស្នាហ៊ានពោលអះអាង ៖

- សូមបងប្រុសទុកចិត្តចុះ ខ្ញុំនឹងនិពន្ធអស់ពីសមត្ថភាព ព្រោះខ្ញុំ អាណិតអាសូរវាសនាអភ័ព្វរបស់ប្រជាជនកម្ពុជាណាស់ ! . .

យើងនៅសំណេះសំណាលជាមួយប្តីប្រពន្ធហ៊ិន រហូតដល់ថ្ងៃជិតលិច ទើបដាច់ចិត្តលាត្រឡប់ទៅវិញ ។

គ្រាន់តែទូកម៉ាស៊ីនចេញផុតពីកំពង់ចម្លង ព្រះអាទិត្យរលត់ផុតរស្មីល្មម ហើយស្បៃងងឹតក៏គ្របដណ្ដប់មកលើផ្ទៃទន្លេសាប ដោយស្រងូតស្រងាត់ ។ ទឹកទន្លេដែលកាលពីថ្ងៃមានពណ៌លៃផង ឥឡូវនេះប្រែ-ក្លាយទៅជាខ្មៅមួយរំពេច ។

រាត្រីនោះ មេឃបាត់ស្ងួនច័ន្ទ . . . ញាំងដួងចិត្តខ្ញុំឲ្យកាន់តែស្រងេះស្រងោចសៀវខ្លោចទើបប្រមាត់ ។ សុភមង្គលនៃសេចក្តីស្នេហា ដែលខ្ញុំធ្លាប់រាប់សិបឆ្នាំមកហើយនោះ ក្លាយទៅជាស្រមោលអណ្តែតតាមគង្គាទៅបាត់អស់រលីង ។ សុបិនល្អ និងសេចក្តីប៉ងប្រាថ្នាគ្រប់បែបយ៉ាងត្រូវជំនួសមកវិញដោយអំពៅជីវិតគួរឲ្យខ្លោចផ្សាក្រៃលែង ។

ការស្ដាយស្រណោះ នៅជក់ជាប់ក្នុងវិញ្ញាណរបស់ខ្ញុំ រហូតដល់ដង្ហើមចុងក្រោយបំផុត ប៉ុន្តែខ្ញុំមិនតូចចិត្តនឹងព្រេងវាសនាដែរ ព្រោះការ



ព្រាត់ប្រាសរវាងខ្ញុំ និង មាលា គឺជាការរួមចំណែកមួយប្រកបដោយកិត្តិយសក្នុងពលិកម្ម ដើម្បីបុព្វហេតុបដិវត្តសង្គមនិយម កសាងសុភមង្គលទុកឲ្យមនុស្សជំនាន់ក្រោយ ។

*

* *

ចប់

ថ្ងៃទី ១៥ ខែ កញ្ញា ១៩៨៥

ទី ស៊ីហួត

និពន្ធនៅមន្ទីរពេទ្យហ្វ៊ស្ត ខេត្ត ខុត្តប៊ុស
សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់